HEINRICH BÖLL STIFTUNG
GUNDA WERNER INSTITUT

វ៉ុលុម ១០

យុត្តិធម៌អន្តរកាល

ទស្សនៈនយោបាយយេនឌ័រសម្រាប់សង្គមក្នុងសម័យអន្តរកាល

ដោយ **Rita Schäfer**

១. សេចក្តីផ្តើម

ការសិក្សានេះវិភាគ អំពីថាតើយេនឌ័រត្រូវបានលើកយកមក ពិចារណាដែរ ឬទេនៅក្នុងសម័យអន្តរកាលបន្ទាប់ពីមានសង្គ្រាម ជម្លោះហឹង្សា និង អំណាចផ្តាច់ការ និងប្រសិនបើមានការពិចាណា តើធ្វើឡើងបែបណា។ សំណួរគន្លឹះដែលលើកឡើងនៅទីនេះគឺៈ តើស្ថាប័ននិងយន្តការយុត្តិធម៌ អន្តរកាល អាច សម្រេចបានយុត្តិធម៌យេនឌ័រកម្រិតណា? សំណួរនេះកើតចេញពីការសន្មតិដែលថា ទម្រង់នានានៃអំពើហឹង្សាខាងយេនឌ័រ ក៏ដូចជា ភាពខុសគ្នាខាងយេនឌ័រ ត្រូវតែលើក យកមកពិចារណាផងដែរ នៅពេលទទួលស្គាល់ពីសង្គ្រាម អំពើហឹង្សាជាទ្រង់ទ្រាយធំ និងការរំលោភធ្ងន់ធ្ងរលើសិទ្ធិមនុស្ស។ មានតែតាមរយៈការធ្វើបែបនេះទេ ទើបអាច កំចាត់ចោលរចនាសម្ព័ន្ធហឹង្សា បង្កើតដំណើរការសន្តិភាពដោយនិរន្តរភាព និងរៀបចំឲ្យ មានយុត្តិធម៌សង្គមទៅបាន។

ដូច្នេះ ប្រការសំខាន់គឺត្រូវប្រកាន់យកទស្សនៈវិភាគដែលទាក់ទងនឹង វិធាន យុត្តិធម៌អន្តរកាល ក៏ដូចជា ស្ថាប័ននានាដែលមានមកទល់ពេលនេះផងដែរ។ អ្វីដែលហៅថា យុត្តិធម៌អន្តរកាល គឺ ជាការកំណត់អំពីរបត់នៃ ការផ្លាស់ប្តូរៈ វាត្រូវតែបន្សុីគ្នាជាមួយអតីតកាល ដោយសារវាជាការស្វែងរកភាពចុះសម្រុងគ្នា ជាមួយការរំលោភធ្ងន់ធ្ងរលើសិទ្ធិមនុស្ស នៅក្នុងអំឡុងពេលកំណត់ជាក់លាក់ តម្រូវឲ្យជនដែដល់ទទួលខុសត្រូវ និងជនរងគ្រោះបានឃើញយុត្តិធម៌។ ទន្ទឹមនឹងនេះ វាជាការស្វែងរកការតម្រង់ទិស សម្រាប់ដំណើរការផ្សះផ្សារ នៅក្នុងសម័យកាលបច្ចុប្បន្ន។ លើសពីនេះ វាជាការគិតទៅខាងមុខ ដោយសារវា មានគោលដៅកែប្រែស្ថានភាព និងរចនាសម្ព័ន្ធសង្គម និងបង្កើតប្រព័ន្ធច្បាប់ថ្មីៗ ឬ គុណតម្លៃខាងសីលធម៌។ ដូច្នេះ ការរួមបញ្ចូល យេនឌ័រជាលក្ខណៈប្រព័ន្ធទៅ ក្នុងកំណែទម្រង់ច្បាប់សំខាន់ៗ អាចជួយកំចាត់ចោលវិសមភាពសង្គម និងសេដ្ឋកិច្ច ដែលធ្លាប់ជាមូលហេតុនៃសង្គ្រាម និងជាមូលហេតុនៃអំពើហឹង្សាខាងយេនឌ័រ។

វិធានកែទម្រង់សុីជម្រៅ ដូចជា ការបង្កើតគោលការណ៍ច្បាប់ និងកំណែទម្រង់ស្ថាប័ន ពេញលេញ ដែលរួមទាំង ការត្រួតត្រាតាមបែបប្រជាធិបតេយ្យលើកងកម្លាំង សន្តិសុខ ត្រូវបានបង្កើតឡើងដើម្បីទប់ស្កាត់អំពើហឹង្សាហួសហេតុដែលកើតឡើងដដែលៗ និងការ រំលោភធ្ងន់ធ្ងរលើសិទ្ធិមនុស្សទៅអនាគត ពីសំណាក់ស្ថាប័នរដ្ឋ (យោធា នគរបាលនិងតុលាការ) និងភ្នាក់ងារក្រៅពីស្ថាប័នរដ្ឋ ។

ដោយសារហេតុផលនេះ ដំណោះស្រាយអន្តរជាតិនានាអំពីដំណើរការសន្តិភាព បាន បង្កើតឲ្យមានយុត្តិធម៌អន្តរកាល និងទិដ្ឋភាពនានាខាងយេនឌ័រអស់រយៈពេលជា ច្រើនឆ្នាំមកហើយ។ ដំណោះស្រាយទាំងនោះបានអំពាវឲ្យនាំយកមកកាត់ទោសតាម ច្បាប់ និងបញ្ឈប់អំពើហឹង្សាខាងផ្លូវភេទមកលើស្ត្រីនៅក្នុងពេលសង្គ្រាម។

អង្គការសហប្រជាជាតិ (អ.ស.ប)ក៏បានចាត់ទុកប្រការនេះជាស្នូលនៃគោលការណ៍ណែនាំរបស់ខ្លួនស្ដីពីយុត្តិធម៌អន្តរកាលផងដែរ។ គោលការណ៍ណែនាំដូចគ្នានេះមានគោលដៅបង្កើតវិធានច្បាប់ និងផ្សារភ្ជាប់ជាមួយសិទ្ធិមនុស្ស។ ទោះជាយ៉ាងណាក៏ដោយនៅតាមកន្លែងជាច្រើន ដោយសារនៅក្នុងស្ថានភាពជាក់ស្ដែង យុត្តិធម៌អន្តរកាលមិនដោះស្រាយបញ្ហាយេនឌ័រឡើយ ដូច្នេះវានាំមកនូវកំណើនវិសមភាព ឋានានុក្រម និងទម្រង់ នៃអំពើហឹង្សានៅក្នុងរយៈពេលមធ្យម និងរយៈពេលវែង។ ការសិក្សានេះពិនិត្យមើលពិស្ដារនូវបញ្ហាទាំងនេះ ក៏ដូចជា ការប្រឈមនានាដែលកើតឡើងផងដែរ។

ការសិក្សានេះពិនិត្យមើលល្អិតល្អន់អំពីការមិនអើពើចំពោះយេនឌ័រនៅក្នុងគោលការណ៍ណែនាំ និងផែនការសកម្មភាពរបស់អាល្លឺម៉ង់ស្ដីពីការគ្រប់គ្រងជម្លោះ ទន្ទឹមនឹងយោងទៅសន្ធិសញ្ញាអន្តរជាតិនានា និងទម្លាប់អនុវត្តខាងការរក្សាសន្តិភាពផងដែរ។ ការសិក្សាអំពីសន្តិភាព និងឯកសារគោលនយោបាយជាច្រើនដែលរៀបចំជាសេចក្ដីព្រាងដោយមជ្ឈមណ្ឌលស្រាវជ្រាវអាល្លឺមង់ ក្នុងនាមជាទីប្រឹក្សានយោបាយ បានវិនិច្ឆ័យខុសចំពោះតួនាទីសំខាន់ៗនៃឋានានុក្រមយេនឌ័រ និងចរិកលក្ខណៈនៃបុរសនៅក្នុងក្របខ័ណ្ឌយោធា។ ប្រការនេះបង្ហាញពីភាពចាំបាច់ដើម្បីពិនិត្យមើលភាពខុសគ្នានៃសក្ដានុពល និងដែនកំណត់នៃលក្ខខណ្ឌនៅក្នុងច្បាប់ និងស្ថាប័នអន្តរជាតិដែលដើរតួជាអ្នកគិតគូរពីអនាគត នៅក្នុងការកសាងគោលនយោបាយ និងបរិធាន ព្រមទាំងយុទ្ធសាស្ត្រសំខាន់ៗនៃយុត្តិធម៌អន្តរកាលដោយផ្អែកតាមទស្សនៈយេនឌ័រ។ ការសិក្សានេះមានគោលដៅជួយនៅក្នុងការធ្វើបែបនេះ។

អំពើហឹង្សាខាងផ្លូវភេទដែលបានអនុវត្តមកលើកុមារា និងបុរស មានគោលដៅ បំផ្លាញ ស្ថិរភាពសង្គម

នៅក្នុងពេលមានសង្គ្រាម ជនល្មោភសង្គ្រាម និងអ្នកឧបត្ថម្ភសង្គ្រាម ភាគច្រើនជាបុរសមានអំណាច ប៉ុន្តែជួនកាល ក៏ជាស្ត្រីនៅក្នុងត្រកូលដែលរងឥទ្ធិពលពីបុរសផងដែរ គឺជាអ្នកបង្កើតឲ្យមានវិសមភាព។ ពួកគេបញ្ជាឲ្យមានការប្រព្រឹត្តអំពើហឹង្សាខាងផ្លូវភេទៈ ភាគច្រើនមកលើស្ត្រី និងកុមារ ប៉ុន្តែជាញឹកញាប់ មកលើបុរស និងកុមារាផងដែរ។ ទម្រង់នានានៃការស្អប់និងការបំបាក់មុខពពួកមនុស្សដែលស្រលាញ់ភេទដូចគ្នា ដែលមានការពាក់ព័ន្ធជាមួយអំពើរំលោភ ដែលប្រព្រឹត្តដោយបុរស និងក្នុងករណីជាច្រើន គឺជាការបំពានលើបំរាមសំខាន់ៗខាងវប្បធម៌ ឬសាសនា ដូច្នេះមានលក្ខណៈជ្រុលហួសហេតុដែលអ្នកស្រាវជ្រាវ អង្គការយេនឌ័រនិងសន្តិភាព បណ្ដាញសុខភាព ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឬយន្តការយុត្តិធម៌អន្តរកាល គ្មានការអធិប្បាយ ហើយសញ្ញាណនៃទម្រង់បទល្មើសបែបនេះក៏ពុំធ្លាប់បានយកមកពិនិត្យ ឬយកមកកាត់ក្ដីក្នុងប្រព័ន្ធតុលាការព្រហ្មទណ្ឌឡើយ។

ការបំពានដោយប្រើអំពើហឹង្សា ដែលផ្តោតលើពលរដ្ឋដែលមានអត្តសញ្ញាណយេនឌ័រខុស គ្នា ឬផ្តោតលើក្រុមមនុស្សដែលមាននិន្នាការណាមួយខាងផ្លូវភេទ សុទ្ធតែពុំមានរួមបញ្ចូលនៅក្នុងយុត្តិធម៌អន្តរកាល ឬ គោលការណ៍ច្បាប់អន្តរជាតិដែលពាក់ព័ន្ធឡើយ។

ការផ្តោតជាទូទៅនៃយុត្តិធម៌អន្តរកាលមកលើអំពើរំលោភលើស្ត្រីដែលជាយុទ្ធសាស្ត្រមួយ ក្នុងសង្គ្រាម មិនបានគិតគូរអំពីប្រការដែលថា ការបំពានដោយអំពើហឹង្សាទាំងនេះក៏ជាទម្រង់ប្រយោលមួយនៃអំពើហឹង្សាមកលើបុរសផងដែរ។ ដូច្នេះប្រការសំខាន់គឺត្រូវរួមបញ្ចូលសញ្ញាណបែបនេះនៃយេនឌ័រទៅក្នុងការគិតគូរផងដែរ។ ជាមួយយុទ្ធសាស្ត្រនេះ ទាហាន ឬអង្គភាពទ័ពព្រៃ បានបំពានលើកត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្លួនឯងដែលជាមនុស្សប្រុស មកលើបុរសនានាដែលមានជាប់ទំនាក់ទំនងជិតស្និទ្ធទៅនឹងជនរងគ្រោះនិងធ្វើឲ្យបាត់បង់ស្ថិរភាពសង្គម។ក្នុងក្របខ័ណ្ឌនៃអត្តសញ្ញាណរួម អំពើរំលោភបែបនេះ ឆ្លុះបញ្ចាំងពីការចុះខ្សោយខាងផ្នែកសាសនា និងសីលធម៌ ឬ សញ្ញាណ និង/ឬ អ្វីដែល ហៅថា ស្ថាប័នជាតិ ដែលមានស្ត្រីជានិមិត្តរូប។

តួអង្គស្ត្រី ត្រូវបានចាត់ទុកជានិមិត្តរូបគន្លឹះមួយនៃការវាយប្រហារនៅក្នុងជម្លោះដោយអំពើហឹង្សា

អត្តសញ្ញាណរួម ពុំត្រូវបានអធិប្បាយឡើយ ប៉ុន្តែត្រូវបានបង្កើតឡើងវិញម្តងហើយម្តងទៀតជាបន្តបន្ទាប់។ យេនឌ័រដើរតួយ៉ាងសំខាន់នៅក្នុងដំណើរការនេះ។ តួអង្គស្ត្រីត្រូវបានចាត់ទុកជាពិសេសថាជានិមិត្តរូបសំខាន់មួយនៃការវាយប្រហារនៅក្នុងជម្លោះដែលមានលក្ខណៈជាតិនិយម ការបែងចែកជាតិសាសន៍ ឬ សាសនានិយម។ ទន្ទឹមនឹងនេះ នៅក្នុងសង្គ្រាមដែលបង្កើតឡើងដើម្បីឈ្លានពានយកដែនដី ដើម្បីទាញយកធនធានរ៉ែ ដីធ្លី ឬ យកទីកន្លែងធ្វើជាទីលានសម្រាប់ចិញ្ចឹមសត្វ មេបញ្ជាការចេញបញ្ជាឲ្យប្រើវិធីរំលោភ ដែលជាយុទ្ធសាស្ត្រដើម្បីបំបាក់មុខ និងបណ្តេញចេញជាក្រុមៗ។ ដូច្នេះ តួអង្គស្ត្រីគឺជាផ្នែកមួយនៃនយោបាយ នៅក្នុងដំណើរការនៃជម្លោះ។ អត្តសញ្ញាណដែលកំណត់តាមប្រពៃណី និងកត្តាពាក់ព័ន្ធជាមួយភាពជាមនុស្សប្រុស ដែលផ្តល់ឲ្យបុរសនូវតួនាទីជាអ្នកការពារស្ត្រី និងកុមារ ត្រូវរងការវាយប្រហារ ដោយសារតែមានការរំលោភបំពានលើស្ត្រី និងដោយសារតែនៅក្នុងករណីនោះ បុរសត្រូវបានបង្ហាញ ថាគ្មានសមត្ថភាពការពារសមាជិកក្នុងគ្រួសាររបស់ខ្លួន។

នៅក្នុងរបបផ្តាច់ការ បុរសដែលតំណាងឲ្យអំណាចរដ្ឋ ដូចជា ទាហាន និងនគរបាល ប្រើប្រាស់វិធីរំលោភ ដោយផ្អែកមូលដ្ឋានប្រហែលគ្នានេះពោលគឺ ការសំដែងអំពីសព្វានុភាពរបស់ខ្លួន និងជាយុទ្ធសាស្ត្រមួយ ដើម្បីបំបាក់មុខសត្រូវ ក៏ដូចជាលើកមោទនភាពក្នុងក្រុមផងដែរ។

ក្នុងករណីខ្លះ ទាហានស្រ្តី និងនគរបាលស្រ្តី ក៏ចូលរួមនៅក្នុងការធ្វើទារុណកម្មខាងផ្លូវភេទ ផងដែរ ឬ មេបញ្ជាការស្រ្តីមួយចំនួនតូច ចេញបញ្ជាឲ្យប្រើប្រាស់ការធ្វើទារុណកម្មបែបនេះ។ ទោះជាយ៉ាងណាក៏ដោយ យន្តការយុត្តិធម៌អន្តរកាលជាច្រើនមិនអាចបង្ហាញឲ្យឃើញពីកត្តាជម្រុញ និងទិដ្ឋភាពនានាដែលមានលក្ខណៈជាក់លាក់និងសម្ងាត់ខាងយេនឌ័រ សូម្បីយន្តការទាំងនោះផ្តោតលើការធ្វើឲ្យខូចខាតជាអចិន្ត្រៃយ៍មកលើចំណងគ្រួសារនិងសង្គម និងធ្វើឲ្យមានការបាក់ស្បាតរយៈពេលវែងក៏ដោយ។ មូលហេតុផ្សេងទៀតដែលនាំឲ្យមានអំពើរបស់ជនរំលោភ ដូចជា ការស្អប់ស្រ្តី ការស្អប់មនុស្សប្រតិព័ទ្ធភេទដូចគ្នា ការសប្បាយនឹងភាពឈឺចាប់របស់អ្នកដទៃ ឬការទូទាត់ចំពោះបរាជ័យរបស់ខ្លួន ច្រើនតែកើតឡើងដោយគ្មានអ្នកណាដឹងឡើយនៅក្នុងដំណើរការយុត្តិធម៌អន្តរកាល។ ការផ្តោតលើបទរំលោភស្រ្តីដែលជាយុទ្ធសាស្រ្តដាច់ដោយឡែកនៃសង្គ្រាម មិនគិតគូរពីទម្រង់ដទៃនៃអំពើហឹង្សាខាងយេនឌ័រជាក់លាក់ឡើយ សូម្បីតែអំពើទាំងនោះកើតមានជាទូទៅក្នុងចំណោមរបបឃោរឃៅ ក៏ដូចជា នៅក្នុងសង្គ្រាម និងជម្លោះហឹង្សាក៏ដោយ។ ជនរងគ្រោះមិនអាចចាត់ទុកបទរំលោភ ថាជាទម្រង់ដាច់ដោយឡែកឡើយ ប៉ុន្តែផ្សារភ្ជាប់អំពើទាំងនោះជាមួយការសំដែងហឹង្សា ដូចជា ការសម្លាប់គោ ការបំផ្លាញផលដំណាំ ឧបករណ៍បច្ចេកទេស ឬផ្ទះសំបែង និងចំពោះជនប្រកាន់ពូជសាសន៍ អ្នកជាតិនិយមជាតិសាសន៍/សាសនា និងការសប្បាយដោយបានប្រមាថអ្នកដទៃ។ អាស្រ័យហេតុនេះ ប្រការសំខាន់ គឺត្រូវយល់អំពីភាពស្មុគ្រស្មាញ និងទំនាក់ទំនងច្រើនយ៉ាងនៃយេនឌ័រ ដើម្បីជំនះទម្រង់នានានៃអំពើហឹង្សាដែលជាសេចក្តីប្រមាថបង្កឡើងដោយកម្លាំងប្រដាប់អាវុធ និងសង្គ្រាម។ ប្រសិនបើវាមិនកើតឡើងទេនោះ គេអាចមានហានិភ័យនៃទម្រង់អំពើហឹង្សានានាខាងយេនឌ័រ និងសកម្មភាពយោធានិយមក្នុងសង្គមទាំងមូល ដែលបន្តនៅក្រោមកាលៈទេសៈថ្មីៗ។

២.១ ការផុសឡើង និងនិយមន័យ

វិធានយុត្តិធម៌អន្តរកាល បានកើតឡើងនៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០និង១៩៩០ ក្នុងពេល ដែលមានកំណើននៃភាពតានតឹងខាងនយោបាយ និងជាលទ្ធផលនៃការដួលរលំអំណាចផ្តាច់ការ ឬ របបកាចសាហាវនៅអាមេរិកឡាទីននិងអឺរ៉ុបខាងកើត។ ក្នុងប្រទេសទាំងនោះ ការបញ្ចប់ជម្លោះរវាងលោកខាងកើតនិងខាងលិច បានធ្វើឲ្យមូលដ្ឋាននៃអំពើហឹង្សាគ្រប់រូបភាពបាត់បង់ទៅផងដែរ។ រដ្ឋាភិបាលដែលបានទទួលសិទ្ធិក្នុង ការផ្តល់អាវុធដល់របបផ្តាច់ការរហូតមកទល់ពេលនោះ ក៏បានឃើញ ថាខ្លួនត្រូវបានបង្ខំចិត្តផ្តល់សេចក្តីពន្យល់ពីអំពើរបស់ខ្លួន ហើយនៅពេលនោះ ត្រូវជួយបើកកាយអំពើឃោរឃៅផងដែរ។

លើសពីនេះ ភាពចលាចលនៅថ្នាក់ជាតិ និងថ្នាក់តំបន់បានបង្ហាញឲ្យឃើញពីភាពស្មុគស្មាញនៃជម្លោះនៅមូលដ្ឋាន ដែលត្រូវការឲ្យមានដំណោះស្រាយ។ មន្ត្រីរដ្ឋាភិបាល ឬ អង្គការសង្គមស៊ីវិល បានអំពាវនាវឲ្យមានការពិនិត្យប្រវត្តិនៃរបបផ្តាច់ការ ក្នុងគោលដៅផ្តល់ឲ្យរបបប្រជាធិបតេយ្យក្មេងខ្ចីនូវឱកាសដើម្បីពង្រឹងជំហរ និងកំណត់និយមន័យអំពីខ្លួនឯងឡើងវិញ។ ទោះជាយ៉ាងណាក៏ដោយ ជោគជ័យនៃកិច្ចការនេះអាស្រ័យលើថា តើឯកសារនានារបស់រដ្ឋនឹងត្រូវចេញផ្សាយជាសាធារណៈដែរឬទេ ឬថាតើស្ថាប័ន និងអ្នកនយោបាយនានាមានឆន្ទៈធ្វើសហប្រតិបត្តិការកម្រិតណា។ សកម្មជនសិទ្ធិមនុស្សក៏ទាមទារឲ្យមានការដាក់ទោសអំពើហិង្សា ដែលបានប្រព្រឹត្តជាលក្ខណៈប្រព័ន្ធពីសំណាក់នគរបាល យោធា និងកម្លាំងសន្តិសុខដទៃទៀត ឬ ក្រុមអត្តឃាដផងដែរ។ ទោះជាយ៉ាងណាក៏ដោយពួកគេមិនចង់ធ្វើឲ្យបាត់បង់ស្ថិរភាពនយោបាយនិងធ្វើឲ្យខូចកំណែទម្រង់វិជ្ជមានណាមួយឡើយ។ ក្នុងន័យនេះ វិធីថ្មីៗដើម្បីឈានទៅសម្រុះសម្រួលជាមួយបទល្មើសធ្ងន់ធ្ងរមកលើសិទ្ធិមនុស្ស បានលេចឡើង ជាពិសេស នៅក្នុងសង្គមនានាដែលក្នុងនោះជនដៃដល់ និងជនរងគ្រោះ ត្រូវបង្ខំចិត្តឲ្យបន្តរស់នៅជាមួយគ្នា ហើយអតីតវរជនបន្តក្តោបក្តាប់អំណាចជាច្រើន ឬ ត្រួតត្រាធនធានសំខាន់ៗផងដែរ។ រូបភាពនៃការកាន់កាប់អំណាចនៅក្នុងប្រទេស បានរារាំងការសើបអង្កេតជាលក្ខណៈប្រព័ន្ធអំពីឧក្រិដ្ឋជននៅក្នុងតំណែងជាន់ខ្ពស់។ អតីតវរជនមានភាពប៉ិនប្រសប់ក្នុងការរារាំងការបើកកកាយឲ្យឃើញរចនាសម្ព័ន្ធអំណាចនៃប្រព័ន្ធឃោរឃៅរបស់ខ្លួន។ អាស្រ័យហេតុនេះ ការវិនិច្ឆ័យករណីនីមួយៗ ពោលគឺភាគច្រើនជាអំពើហិង្សាធ្ងន់ធ្ងរបំផុត បានក្លាយជាចំណុចនៃការយកចិត្តទុកដាក់។ គណៈកម្មការស្វែងរកការពិត និងសម្រុះសម្រួល ត្រូវបានបង្កើតឡើងនៅក្នុងប្រទេសនានា ដែលគ្មានភាគីណាមួយនៅក្នុងជម្លោះអាចកំណត់បានជាអ្នកឈ្នះដាច់ខាតឡើយ ហើយកិច្ចព្រមព្រៀងសន្តិភាពគឺជាលទ្ធផលនៃការចរចាស្វែងរកផ្លូវកណ្តាល (Marx 2007)។ ការស្រាវជ្រាវដោយអ្នកវិទ្យាសាស្ត្រនយោបាយអំពីអន្តរកាល ដែលភាគច្រើនត្រូវបានវិភាគដោយអ្នកស្រាវជ្រាវអាមេរិក ដែលផ្តោតលើអន្តរកាលពីអំណាចផ្តាច់ការ ទៅរបបប្រជាធិបតេយ្យនិងសេដ្ឋកិច្ចទីផ្សារសេរី បានរួមបញ្ចូលគណៈកម្មការនានាបែបនេះ នៅក្រោមឈ្មោះមិនច្បាស់លាស់មួយ "យុត្តិធម៌អន្តរកាល" បន្តពីឈ្មោះមិនច្បាស់លាស់មួយផ្សេង "អន្តរកាលទៅរកប្រជាធិបតេយ្យ" ដែលជាឈ្មោះនិយមប្រើប្រាស់នៅក្នុងឯកសារវិទ្យាសាស្ត្រ។

សង្គ្រាមនៅក្នុងអតីតយូហ្គោស្លាវី ក៏ត្រូវការឲ្យមានដំណោះស្រាយថ្មីៗផងដែរ

ទោះជាយ៉ាងណាក៏ដោយ ភាពចលាចលនៅអឺរ៉ុបខាងកើត អាមេរិកឡាទីន ឬ តំបន់នានានៅអាហ្វ្រិក មិនត្រឹមតែបានជួយដល់យន្តការយុត្តិធម៌អន្តរកាលឲ្យបង្ហាញខ្លួនប៉ុណ្ណោះទេ ប៉ុន្តែសង្គ្រាមនៅក្នុងអតីតយូហ្គោស្លាវីនៅដើមទសវត្សរ៍ឆ្នាំ ១៩៩០ ក៏ដូចជាការសម្លាប់រង្គាលដែលកើតឡើងនៅរ៉្វាន់ដា ក្នុងឆ្នាំ ១៩៩៤ បានអំពាវនាវឲ្យមានដំណោះស្រាយថ្មីៗផងដែរ។

ដូច្នេះ អ្នកនិពន្ធខ្លះ បានបង្ហាញភាពខុសគ្នារវាងស្ថាប័នយុត្តិធម៌អន្តរកាលដែលកើតឡើងនៅមុនឆ្នាំ១៩៩០ និងស្ថាប័នដែលកើតឡើងនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ នៅពេលដែលសហគមន៍អន្តរជាតិកាត់ទោសអ្នកដែលទទួលខុសត្រូវចំពោះអំពើសម្លាប់រង្គាលនិងឧក្រិដជនសង្គ្រាម នៅក្នុងតុលាការព្រហ្មទណ្ឌ។ ស្ថាប័នទាំងនេះបានកើតឡើងបន្ទាប់ពីមានវិធីជាច្រើននៃការកាត់ក្តី និងការសម្រុះសម្រួលក្រៅប្រព័ន្ធតុលាការត្រូវបានយកមកអនុវត្ត នៅក្នុងការដោះស្រាយអំពើព្រហ្មទណ្ឌទាំងឡាយដែលមានជាហូរហែរចាប់ពីចុងទសវត្សរ៍ឆ្នាំ ១៩៩០តមក ដែលនៅតាមកន្លែងខ្លះ បានកើតឡើងជាបន្តបន្ទាប់យ៉ាងឆាប់រហ័ស ឬ នៅក្នុងពេលតែមួយជាមួយគ្នាថែមទៀតផង។

បច្ចុប្បន្ននេះ យុត្តិធម៌អន្តរកាលគឺជាពាក្យដែលបានបង្កើតឡើងនៅ ក្នុង នយោបាយអន្តរជាតិ ដែលជាការពិតវាគឺជាការស្រាវជ្រាវអំពីសន្តិភាព និងជម្លោះ ទោះបីមាននិយមន័យ និងការបកស្រាយខុសៗគ្នានៅក្នុងអត្ថបទនានាក៏ដោយ។ វាផ្សំដោយស្ថាប័ននិងយន្តការជាច្រើនបែបដែលនៅក្នុងពេលនេះត្រូវបានយកមកអនុវត្តនៅក្នុងស្ថានភាពខុសៗគ្នា និងក្នុងគោលដៅខុសគ្នាផងដែរ។

យុត្តិធម៌អន្តរកាលមានភាពលេចធ្លោដោយសារតែពហុភាព ទំនាក់ទំនង និងលក្ខខណ្ឌរបស់វា ព្រមទាំងមានហានិភ័យនៃការដែលអាចត្រូវគេយកមកប្រើប្រាស់សម្រាប់គោលដៅនយោបាយផងដែរ។ ទិដ្ឋភាពខុសៗគ្នាជាច្រើននៃបញ្ហាដែលមានចរិតលក្ខណៈជាដំណើរការក្នុងអន្តរកាល ខាងនយោបាយ ច្បាប់ និងសង្គម ក៏ដូចជា ការជជែកវែកញែកបែបប្រកួតប្រជែង អំពីការចងចាំនូវផលវិបាកនៃរបបឃោរឃៅ ឬ ជម្លោះប្រដាប់អាវុធ បង្ហាញឲ្យឃើញពីភាពដាច់ដោយដុំ និងដែលគ្មានលក្ខណៈឯកភាពគ្នា នៃសញ្ញាណសម្រាប់ពាក្យយុត្តិធម៌អន្តរកាល។

ការយកចិត្តទុកដាក់ត្រូវបានពង្រីកដើម្បីរួមបញ្ចូលអំពើហឹង្សានៅក្នុងអំឡុងសង្គ្រាមស៊ីវិលនិងក្នុងរដ្ឋទន់ខ្សោយនានា

រហូតដល់ពាក់កណ្តាលសតវត្សរ៍ទី២០ មានការយកចិត្តទុកដាក់ស្របគ្នាផងដែរជាមួយពាក្យឧក្រិដ្ឋកម្មសង្គ្រាម ឬអំពើហឹង្សាបង្កដោយរដ្ឋ ដែលអាស្រ័យលើបរិបទជាក់លាក់នៃប្រទេសខុសគ្នា និងស្ថានភាពនៃអំណាចនៅក្នុងប្រវត្តិសាស្ត្រ និងបានផ្តោតលើការកាត់ទោសជនដែដល់នៅក្នុងតំណែងជាន់ខ្ពស់ ឬ អ្នកឧបត្ថម្ភដល់អំពើហឹង្សានៅក្នុងរដ្ឋាភិបាលសាមី។ នេះជាករណីជាក់ស្តែង ឧទាហរណ៍ នៅក្នុងសាលាក្តី នូរេមបឺក និងសាលាក្តីឧក្រិដ្ឋកម្មសង្គ្រាមតូក្យូ។ នៅទសវត្សរ៍ឆ្នាំ ១៩៨០ វិធាននេះត្រូវបានពង្រីក ដោយរួមបញ្ចូលអំពើហឹង្សាធ្ងន់ធ្ងរលើសិទ្ធិមនុស្ស ដូចក្នុងករណីនៃបណ្តាប្រទេសនៅអាមេរិកឡាទីនដែលបានចាត់ចែងឡើងក្នុងនាមរដ្ឋទាំងនោះ។

ចាប់ពីពេលនោះមក ការយកចិត្តទុកដាក់ត្រូវបានពង្រីក និងកែប្រែ។ ឧទាហរណ៍ បច្ចុប្បន្ននេះ ការសង្កត់ធ្ងន់មិនមែនត្រឹមតែលើអន្តរកាលពីរបបផ្តាច់ការទៅប្រជាធិបតេយ្យ និងរចនាសម្ព័ន្ធនយោបាយថ្មី ដោយផ្តន្ទាទោស ឬ ធ្វើនិរទ្ទេសជនប្រព្រឹត្តិអំពើហឹង្សាប៉ុណ្ណោះទេ ប៉ុន្តែក៏ផ្តោតលើការដោះស្រាយអំពើហឹង្សានៅក្នុងសង្គ្រាមស៊ីវិល ឬ រដ្ឋទន់ខ្សោយនានាផងដែរ។

ការប្រែប្រួលនេះមួយផ្នែក កើតឡើងដោយសារកំណែទម្រង់ដែលបានធ្វើឡើងដោយផ្អែកលើច្បាប់អន្តរជាតិ ដូចជា អនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៨ អនុសញ្ញាក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ក៏ដូចជា ពិធីសារបន្ថែមនៅឆ្នាំ ១៩៧៧ និងលក្ខន្តិកៈទីក្រុងរ៉ូម ឆ្នាំ១៩៩៨ ដែលជាមូលដ្ឋាននៃការបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិនៅទីក្រុងឡាអេផងដែរ។ យុត្តិធម៌ឧក្រិដ្ឋកម្មអន្តរជាតិ កាន់តែត្រូវបានប្រើប្រាស់ដើម្បីនាំអ្នកទាំងឡាយណាដែលប្រព្រឹត្តិ ឬ ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងអំពើហឹង្សាធ្ងន់ធ្ងរលើសិទ្ធិមនុស្ស មកកាត់ទោស និងដើម្បីដោះស្រាយការលើកលែងទោសជាទូទៅ ដែលមានប្រើប្រាស់យ៉ាងច្រើនផងដែរ។ ទោះជាយ៉ាងណាក៏ដោយ លើកលែងតែក្នុងការវិនិច្ឆ័យក្តីនៅឆ្នាំ ១៩៧៤ លើរបបយោធាក្នុងប្រទេសក្រិក ការលើកលែងទោសបែបនេះបានធ្វើឡើងជាទូទៅ រហូតដល់ទសវត្សរ៍ឆ្នាំ១៩៨០ ជាពិសេសនៅពេលដែលជនផ្តាច់ការចុះចេញពីតំណែង នៅក្រោយមានការចរចារកផ្លូវកណ្តាល។ ការប្រែប្រួលនានានៅក្នុងនិយាមនៃច្បាប់អន្តរជាតិ បានកើតចេញពីកិច្ចផ្តួចផ្តើមរបស់អង្គការសិទ្ធិមនុស្ស។ អង្គការទាំងនេះបានទាក់ទងមកតុលាការសិទ្ធិមនុស្សអន្តរទ្វីបអាមេរិក និងអង្គការសហប្រជាជាតិ។ ការកែប្រែនិយាមនៅក្នុងច្បាប់ បានបង្កើតចេញជាស្ថាប័នច្បាប់ថ្មីៗដើម្បីឲ្យមានការសម្រុះសម្រួលជាមួយអំពើហឹង្សាខាងនយោបាយ និងបទល្មើសធ្ងន់ធ្ងរខាងសិទ្ធិមនុស្ស។ ទោះជាយ៉ាងណាក៏ដោយ បច្ចុប្បន្ននេះ អង្គការសង្គមស៊ីវិល និងអ្នកវិទ្យាសាស្ត្របានចូលរួមនៅក្នុងការជជែកវែកញែកអំពីថាតើគំរូណាមួយនៃយុត្តិធម៌អន្តរកាល មានប្រយោជន៍នៅក្នុងបរិបទណា ដោយមានការទទួលស្គាល់អំពីកំហុសឆ្គង និងបញ្ហាជារចនាសម្ព័ន្ធដែលមានកាន់តែច្រើនឡើង។ ទន្ទឹមនឹងនេះ ការជជែកវែកញែក និងការទាមទារខាងនយោបាយរបស់ពួកគេ បានប្តូរពីការផ្តោតលើការកាត់ទោសជនល្មើស/រដ្ឋ មករកជនរងគ្រោះនៅក្នុងសកម្មភាពនានា ដើម្បីឲ្យមានការសម្រុះសម្រួល និងដោះស្រាយអំពើហឹង្សាដែលពុំមានចែងនៅក្នុងប្រព័ន្ធច្បាប់។ ប្រការនេះបានបង្កើតឲ្យមានភាពមិនចុះសម្រុងគ្នាថ្មីៗផងដែរ។

យេនឌ័រនៅក្នុងយុត្តិធម៌អន្តរកាល ពុំមានចែងឡើយរហូតដល់ ទសវត្សរ៍ឆ្នាំ ១៩៩០។ កត្តាជម្រុញចំបងៗ ដែលនាំឲ្យមានការអភិវឌ្ឍបែបនេះ គឺស្ត្រីអ្នកវិទ្យាសាស្ត្រនិងអង្គការសិទ្ធិស្ត្រីនានា ជាពិសេស នៅក្នុងបណ្តាប្រទេសដែលស្ថិតក្នុងស្ថានភាពក្រោយជម្លោះនៅអាហ្វ្រិកខាងត្បូង រ៉្វាន់ដា និងអតីតយូហ្គោស្លាវី។ ការពង្រឹងនូវការទាមទារនៅក្នុងវិធាន និងយន្តការនានានៃយុត្តិធម៌អន្តរកាល តាមរយៈច្បាប់ស្ថាប័ន និងសញ្ញាណនានាជាអន្តរជាតិ គឺជាដំណើរការដ៏លំបាក ជាប់ជាប្រចាំដែលផ្សារភ្ជាប់ជាមួយការមិនអើពើ និងភាពមានៈ។ នៅក្នុងករណីដែលមានការគិតគូរអំពីយេនឌ័រ ការយកចិត្តទុកដាក់បានផ្តោតជាចំបងលើស្ត្រីដែលជាជនរងគ្រោះ។

សញ្ញាណនៃយុត្តិធម៌អន្តរកាលរបស់អង្គការសហប្រជាជាតិរួមបញ្ចូលខ្លឹមសារនៃការរំលោភលើសិទ្ធិមនុស្សខុសៗគ្នា

អង្គការសហប្រជាជាតិឲ្យនិយមន័យយុត្តិធម៌អន្តរកាលជា "ដំណើរការ និងយន្តការទាំងអស់ដែលពាក់ព័ន្ធជាមួយការប៉ុនប៉ងរបស់សង្គមក្នុងការទទួលយកមរតកនៃការរំលោភបំពានជាទ្រង់ទ្រាយធំក្នុងពេលកន្លងមក ដើម្បីធានាឲ្យមានគណនេយ្យភាពយុត្តិធម៌ និងសម្រេចបានការផ្សះផ្សារ។ វាគ្របដណ្តប់ទាំងដំណើរការនិងយន្តការតាមផ្លូវតុលាការ និងក្រៅផ្លូវតុលាការ ដែលរួមទាំង កិច្ចផ្តួចផ្តើមដើម្បីកាត់ទោស ការសម្រួលឲ្យមានកិច្ចផ្តួចផ្តើមដែលទាក់ទងនឹងសិទ្ធិក្នុងការដឹងពីការណ៍ពិត ការផ្តល់សំណងកំណែទម្រង់ស្ថាប័ន និងការពិគ្រោះយោបល់នៅថ្នាក់ជាតិ"។ វិធានការនីមួយៗត្រូវតែគោរពតាមនិយាមច្បាប់ និងសិទ្ធិមនុស្សអន្តរជាតិ។

សញ្ញាណនៃយុត្តិធម៌អន្តរកាលរបស់អង្គការសហប្រជាជាតិ ឆ្នាំ២០១០ បានផ្តោត ជាសំខាន់លើការបង្កើតស្ថាប័ននានានៅក្នុងបណ្តាប្រទេសដែលស្ថិត ក្នុងស្ថានភាពក្រោយជម្លោះ ទៅតាមគោលការណ៍ច្បាប់។ សន្តិភាព និងយុត្តិធម៌គួរតែបំពេញឲ្យគ្នាទៅវិញទៅមក ទន្ទឹមនឹងការចាំបាច់ដើម្បីពិចារណាអំពីបរិបទរបស់ប្រទេសសាមីផងដែរ។ ដំណើរការយុត្តិធម៌អន្តរកាល ក៏គួរតែមានគោលដៅលុបបំបាត់ការរំលោភលើសិទ្ធិសង្គមកិច្ច និងសេដ្ឋកិច្ចផងដែរ។ ការរួមបញ្ចូលបទរំលោភលើសិទ្ធិមនុស្សតាមទម្រង់ជាច្រើននៅក្នុងក្របខ័ណ្ឌបែបនេះ គឺជាសញ្ញាសំគាល់នៃសញ្ញាណរបស់អង្គការសហប្រជាជាតិ ដែលរដ្ឋជាច្រើន និងភ្នាក់ងារក្នុងសង្គមស៊ីវិលបានបង្ហាញពីការឆ្លើយតបត្រឹមតិចតួចប៉ុណ្ណោះ ដែលរួមទាំង ប្រទេសអាល្លឺម៉ង់ផងដែរ។ ការរួមបញ្ចូលបែបនេះអាចដោះស្រាយបានត្រឹមតែមួយផ្នែកប៉ុណ្ណោះ នៅក្នុងការស្រាវជ្រាវអំពីសន្តិភាពនិងជម្លោះ ចំណែកករណីលើកលែងដែលគួរឲ្យកត់សំគាល់មួយនៅក្នុងបរិបទនេះ គឺការសិក្សាអំពីសន្តិភាពដោយគិតគូរអំពីយេនឌ័រ។ អ.ស.បសង្កត់ធ្ងន់ថា៖ យេនឌ័រគួរតែដើរតួយ៉ាងសំខាន់នៅក្នុងដំណើរការនៃការសម្រុះសម្រួលជាមួយឧក្រិដ្ឋកម្មសង្គ្រាមនិង

ការរំលោភសិទ្ធិមនុស្ស យុត្តិធម៌យេនឌ័រគឺជាគោលដៅមួយនៃដំណើរការកសាងសន្តិភាព និងសង្គមនៅក្រោយសម័យសង្គ្រាម។ ក្នុងបរិបទនេះ គោលការណ៍ណែនាំរបស់អ.ស.ប និងរបាយការណ៍ស្តីពីយុត្តិធម៌អន្តរកាល យោងទៅសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិ លេខ១៣២៥, ១៨២០, ១៨៨៨, ១៨៨៩, ១៩៦០, ២០១៦ និង ២០២២ ដែលបានអនុម័តនៅក្នុងឆ្នាំ ២០០០ ដល់ ២០១៣ ស្តីពី "ស្រ្តី សន្តិភាព និងសន្តិសុខ"។ ដោយឡែក ប្រការនេះទាក់ទងនឹងការវិនិច្ឆ័យទោសព្រហ្មទណ្ឌលើអំពើហឹង្សាខាងផ្លូវភេទ ដែលទាក់ទងនឹងសង្គ្រាម និងការលើកកំពស់ស្រ្តី នៅក្នុងគណៈកម្មាធិការសន្តិភាព។6 ស្រ្តីគួរតែពាក់ព័ន្ធនៅក្នុងដំណើរការកសាងផែនការ ការអនុវត្ត តាមដាន និងវាយតម្លៃយុត្តិធម៌អន្តរកាលទាំង អស់ដូចជា គណៈកម្មការស្វែងរកការណ៍ពិត និងផ្សះផ្សារ និងកម្មវិធីសំណងការខូចខាត និងនៅក្នុងការបង្កើតគោលការណ៍ច្បាប់ ដើម្បីមានឥទ្ធិពលមកលើកំណែទម្រង់ និងការបង្កើត ស្ថាប័នរដ្ឋតាមវិធីដែលមានសមធម៌ខាងយេនឌ័រផងដែរ។

ការធ្វើបែបនេះគួរតែអាចកែលម្អជាមូលដ្ឋាននូវការប្រើប្រាស់ស្ថាប័នរដ្ឋដើម្បី ស្រ្តី និងបុរស ដែលយោងតាមការប៉ាន់ស្មានរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ បានរងគ្រោះជាពិសេស ដោយសារអំពើហឹង្សាដែលទាក់ទងនឹងសង្គ្រាម និងគួរតែអាចសម្រួលដល់ការកាត់ទោសព្រហ្មទណ្ឌលើអំពើហឹង្សាខាងយេនឌ័រដោយសារសង្គ្រាម។ សេចក្តីសម្រេចលេខ ១៨២០ ដែលអនុម័តដោយក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិនៅឆ្នាំ ២០០៨ យ៉ាងហោចណាស់ បានឲ្យនិយមន័យ ការរំលោភ ជាឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ នៅឆ្នាំ ២០១០ អគ្គលេខាធិការអង្គការសហប្រជាជាតិបាន គឺមូន បានតែងតាំងតំណាងពិសេសខាងអំពើហឹង្សាខាងផ្លូវភេទនៅក្នុងជម្លោះដែលត្រូវរាយការណ៍ជាទៀងទាត់ និងចងក្រងអំពីការប្រឈម និងបរាជ័យនានា។ របាយការណ៍សម្រេចនៃសម័យប្រជុំលើកទី ៥៧ នៃគណៈកម្មការអ.ស.បស្តីពីស្ថានភាពស្រ្តីនៅខែមីនា ឆ្នាំ២០១៣ បានអំពាវនាវឲ្យមានការកាត់ទោសនិងដាក់ទណ្ឌកម្មចំពោះអំពើហឹង្សាខាងយេនឌ័រដែលទាក់ទងនឹងសង្គ្រាម។ ជនរងគ្រោះគួរតែបានទទួលសំណងប្រសើរជាងមុន និងជំនួយខាងផ្លូវច្បាប់បានច្រើនជាងមុន។ របាយការណ៍របស់អគ្គលេខាធិការអ.ស.ប ដែលបានចេញផ្សាយនៅខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការអនុវត្តសេចក្តីសម្រេចរបស់អ.ស.ប លេខ ១៣២៥ និងសេចក្តីសម្រេចជាបន្តដែលផ្អែកលើសេចក្តីពិស្តាររបស់ខ្លួន ស្តីពីសារៈសំខាន់នៃយេនឌ័រនៅក្នុងយុត្តិធម៌អន្តរកាល។

ដើម្បីសន្តិភាពយូរអង្វែង៖ ត្រូវលុបបំបាត់ឋានានុក្រមយេនឌ័រ

សញ្ញាណយុត្តិធម៌អន្តរកាលនៃអ.ស.ប និងរបាយការណ៍ពាក់ព័ន្ធរបស់អ.ស.ប ផ្សារភ្ជាប់សារៈសំខាន់នេះនៃ ការកំចាត់ចោលការរើសអើងខាងសេដ្ឋកិច្ច និងសង្គម មកលើស្ត្រី។ នៅទីបំផុត អំពើហឹង្សាខាងយេនឌ័រដែលទាក់ទងនឹង សង្គ្រាម បង្កើនវិសមភាពយេនឌ័រ ដែលបានបង្កើតរួចមកហើយនៅក្នុងសង្គមសម័យ មុន សង្គ្រាម និងស្ថិតក្នុងចំណោមមូលហេតុនានា ដែលនាំឲ្យសង្គ្រាមផ្ទុះឡើង។ នៅសម័យក្រោយសង្គ្រាម ឋានានុក្រមយេនឌ័រ រារាំងស្ត្រីពីការទទួលបានយុត្តិធម៌ និង ការចូលរួមយ៉ាងសកម្មនៅក្នុងកំណែទម្រង់ និងដំណើរការធ្វើសេចក្តីសម្រេច។ អង្គការ សហប្រជាជាតិបានទទួលការអំពាវនាវឲ្យជួយបង្កើតយុត្តិធម៌យេនឌ័រ និងលើកកំពស់ ស្ត្រីក្នុងការទទួលបានសិទ្ធិ។

វិធានយុត្តិធម៌អន្តរកាលសំខាន់បំផុតមានការយល់ដឹងក្នុងកម្រិតកំណត់អំពីយេនឌ័រ

វិធានយុត្តិធម៌អន្តរកាលសំខាន់បំផុតមានបង្ហាញខាងក្រោម។ និយមន័យ នានាត្រូវបានបង្កើតឡើងដោយ មជ្ឈមណ្ឌលអន្តរជាតិដើម្បីយុត្តិធម៌អន្តរកាល(ICTJ)ដ៏ល្បីល្បាញនៅក្រុងញូវយក ដែលណែនាំស្ថាប័នរដ្ឋនានា និងអ្នកកសាងគោល នយោបាយអន្តរជាតិ ជាតិនិងមូលដ្ឋាន រៀបចំការវិភាគ និងកិច្ចការនានាដែល ទាក់ទងនឹងសាវតា នៅក្រោមភាពជាដៃគូជាមួយអង្គការសិទ្ធិស្ត្រី/មនុស្សនៅក្នុងប្រទេសដែលស្ថិតក្នុងស្ថានភាពជម្លោះ។ ផ្ទុយនឹងគោលការណ៍ណែនាំរបស់អ.ស.ប វិធាននានាទាំងនេះ មិនបានគិតគូរអំពី ទិដ្ឋភាពភាគច្រើននៃយេនឌ័រឡើយ។ ទោះជាយ៉ាងណាក៏ដោយ វិធានទាំងនោះត្រូវបានអ្នក ស្រាវជ្រាវអន្តរជាតិ និងគោល នយោបាយក្នុងវិស័យសន្តិភាពទទួលយក។ បច្ចុប្បន្ននេះ យុត្តិធម៌អន្តរកាលផ្សំដោយវិធាន និងគោលដៅនានាដូចតទៅ៖

ការកាត់ទោសបទព្រហ្មទណ្ឌ៖ ការស៊ើបអង្កេតដោយចៅក្រម និងការវិនិច្ឆ័យក្តីក្នុងប្រព័ន្ធតុលាការ ដើម្បីស្វែងរកការកាត់ទោសអ្នកដែលទទួលខុសត្រូវជាបឋមលើបទ រំលោភធ្ងន់ធ្ងរ និងជាលក្ខណៈប្រព័ន្ធលើសិទ្ធមនុស្ស និងឧក្រិដ្ឋកម្មដទៃទៀត។

គណៈកម្មការស្វែងរកការណ៍ពិតនិងការផ្សះផ្សារ៖ មានគោលដៅបើកកកាយអំពីអំពើហឹង្សានានាពីអតីតកាល និងបង្កលក្ខណៈងាយស្រួលសម្រាប់ដំណើការផ្សះផ្សារជាសម្រាប់បុគ្គល ក៏ដូចជា សម្រាប់ជាតិផងដែរ។ ការចងក្រងអំពីអ្វីដែលបានកើតឡើងនៅក្នុងអំឡុងពេលមានសង្គ្រាម ក៏ដូចជាអំពើហឹង្សានានា រួមចំណែកក្នុងការបង្កើនការយល់ដឹងរួមគ្នា។ ក្នុងករណីជាច្រើន គណៈកម្មការទាំងនេះបង្កើតឲ្យមានវេទិកាក្រៅតុលាការសម្រាប់សវនការប្រជាជន ដែលពាក់ព័ន្ធជាមួយជនរងគ្រោះ ក៏ដូចជាសាកស្សួរជនដៃដល់ផងដែរ។ គណៈកម្មការទាំងនេះលើកអនុសាសន៍ដើម្បីសុំការលើកលែងទោស ឬ វិនិច្ឆ័យទោសព្រហ្មទណ្ឌ។

ជាញឹកញាប់ គណៈកម្មការនានាបង្កើតគណៈកម្មាធិការផ្ដល់សំណង ឬ ស្ថានីតិសម្បទាដែលបង្វែរការទាមទារជាក់លាក់ទៅរដ្ឋាភិបាលដែលកាន់អំណាចនៅសម័យក្រោយមានជម្លោះ។ តាំងពីទសវត្សរ៍ឆ្នាំ ១៩៩០មក គណៈកម្មការស្វែងរកការណ៍ពិតនិងការផ្សះផ្សារ ត្រូវបានប្រើប្រាស់ជាច្រើនលើក ជាវិធានជំនួស ឬបំពេញបន្ថែមលើនីតិវិធីព្រហ្មទណ្ឌ(អន្តរ)ជាតិ ឬ ជាសាលាក្ដីពិសេសនៅថ្នាក់ជាតិ។

សំណង៖ នេះជាវិធានការដែលផ្ដួចផ្ដើមដោយរដ្ឋ ដើម្បីទូទាត់សំណងទៅឲ្យជនរងគ្រោះនៃអំពើហឹង្សា ឬ សាច់ញាតិរបស់ជនរងគ្រោះដែលរងការធ្វើឃាដ។ ជាញឹកញាប់ គណៈកម្មការស្វែងរកការណ៍ពិតនិងផ្សះផ្សារ ផ្ដល់ការលើកទឹកចិត្តឲ្យធ្វើបែបនេះ។ សំណងអាចជាហិរញ្ញវត្ថុ និងជានិមិត្តរូប។

កំណែទម្រង់វិស័យសន្តិសុខ៖ គ្រឹះស្ថានជាតិ ដូចជា យោធា នគរបាល និងតុលាការគួរតែបានកែប្រែយ៉ាងច្រើន ដើម្បីធានាថា អំពើហឹង្សាដែលមានលក្ខណៈជាស្ថាប័នទម្រង់នៃអំពើឃោរឃៅ ក៏ដូចជា អំពើពុករលួយ ត្រូវបានលុបបំបាត់។ គោលការណ៍ច្បាប់ត្រូវយកមកអនុវត្តឲ្យបានស្មើគ្នា។

"ការចងចាំ"៖ ពាក្យនេះផ្សំដោយកិច្ចផ្ដួចផ្ដើមដើម្បីប្រឹងប្រែង បង្កើតវប្បធម៌នៃការចងចាំ ពោលគឺ ការប្រារព្ធពិធីរំលឹកនៅថ្នាក់ជាតិ ឬ ជាសមូហភាព។ ប្រការនេះរាប់បញ្ចូលពិធីរំលឹក និងសារមន្ទីរដែលបង្កើតឡើងដើម្បីជួយបង្កើនការយល់ដឹង ការសម្រុះសម្រួលជាមួយបទរំលោភសិទ្ធិមនុស្សពីអតីតកាល និងទប់ស្កាត់មិនឲ្យកើតជាថ្មី។ ការលើកលែងទោសៈ ក្នុងន័យធម្មតា គេត្រូវបែងចែកភាពខុសគ្នារវាងការលើកលែងទោសជាទូទៅ និងជាលក្ខណៈបុគ្គល។ ការលើកលែងទោសជាទូទៅផ្អែកលើសន្ធិសញ្ញាសន្តិភាព ឬ ច្បាប់ស្ដីពីការលើកលែងទោសដែលមានអានុភាពមកលើនិទណ្ឌភាពសម្រាប់គ្រប់ឧក្រិដ្ឋកម្មសង្គ្រាម ដែលប្រព្រឹត្តនៅក្នុងអំឡុងពេលកំណត់ណាមួយ។ ការលើកលែងទោសបែបនេះគឺជាការពង្រឹងសន្តិភាពដែលមានលក្ខណៈផុយស្រួយ និងប្រជាធិបតេយ្យដែលនៅក្មេងខ្ចី។ ផ្ទុយទៅវិញ ការលើកលែងទោសជាលក្ខណៈបុគ្គល អាចធ្វើទៅបាន ដូចជា តាមរយៈគណៈកម្មការស្វែងរកការណ៍ពិត និងផ្សះផ្សារ។ ទោះជាយ៉ាងណាក៏ដោយ សន្ធិសញ្ញាអន្តរជាតិទាមទារឲ្យកាត់ទោសអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

យុត្តិធម៌យេនឌ័រ៖ កិច្ចប្រឹងប្រែងដើម្បីលុបបំបាត់និទណ្ឌភាពនៃអំពើហឹង្សាខាងផ្លូវភេទ និងខាងយេនឌ័រ ត្រូវបានរួមបញ្ចូលនៅក្នុងការទាមទារតែមួយ។ គេត្រូវធានាថា ស្ត្រីដែលធ្លាក់ខ្លួនជាជនរងគ្រោះដោយសារអំពើហឹង្សា ត្រូវតែបានទទួលលទ្ធភាពស្មើគ្នានៅក្នុងកម្មវិធីទទួលសំណង បន្ទាប់ពីរងអំពើរំលោភលើសិទ្ធិមនុស្ស។

៣.១ វិធាន និងស្ថាប័ននានានៅថ្នាក់អន្តរជាតិ និងថ្នាក់ជាតិ

៣.១.១ សាលាក្តីពិសេស

នៅក្រោយសង្គ្រាមលោកលើកទីពីរ ការកាត់ក្តីឧក្រិដ្ឋកម្មសង្គ្រាមសំខាន់ៗបានធ្វើឡើងនៅនូរេមប៊ឺក និងតូក្យូ រវាងឆ្នាំ១៩៤៥ និង ១៩៤៩។ សាលាក្តីនោះត្រូវបានបង្កើតឡើងដើម្បីបង្ខំឲ្យជនដែលដល់ទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន និងបញ្ចប់និទណ្ឌភាព។ ទោះជាយ៉ាងណាក៏ដោយអំពើហឹង្សាខាងផ្លូវភេទនៅក្នុងសម័យសង្គ្រាមមិនត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មដោយផ្ទាល់ឡើយ នៅក្នុងពេលកាត់ក្តីណាមួយខាងលើ (Bell/O'Rourke 2007: 26ff.)។ នៅឆ្នាំ ១៩៩៣ សាលាក្តីអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី(ICTY) បានចាប់ផ្តើមការងាររបស់ខ្លួននៅទីក្រុងឡាអេ ទៅតាមសេចក្តីសម្រេចរបស់អ.ស.បលេខ ៨២៧, សាលាក្តីអន្តរជាតិសម្រាប់រ្វ៉ាន់ដា (ICTR) នៅអារូស្សា ប្រទេសតង់ហ្សានី បានធ្វើឡើងនៅឆ្នាំ ១៩៩៥ យោងទៅតាមសេចក្តីសម្រេចរបស់អ.ស.ប លេខ ៩៥៥។ សាលាក្តីទាំងពីរនេះ គឺជាសកម្មភាពដំបូងដើម្បីចាត់ជាជំពូក និងថ្កោលទោសចំពោះអំពើហឹង្សាខាងផ្លូវភេទជាឧក្រិដ្ឋកម្មសង្គ្រាម។ នេះជាការផ្តល់មូលដ្ឋានសម្រាប់អនុសញ្ញា ដែលជាប់កាតព្វកិច្ចជាអន្តរជាតិស្តីពីការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងប្រឆាំង ស្ត្រី (CEDAW) ដែលបានអនុម័តនៅឆ្នាំ ១៩៧៩។ បន្ថែមលើនេះគឺ សេចក្តីថ្លែងការណ៍ចុងក្រោយនៃសន្និសីទពិភពលោកស្តីពីសិទ្ធិមនុស្សនៅទីក្រុងវីយែន ឆ្នាំ ១៩៩៣ ដែល បានចាត់ទុកសិទ្ធិស្ត្រីជាសិទ្ធិមនុស្ស និងបានថ្កោលទោសអំពើហឹង្សាខាងយេនឌ័រ។ សេចក្តីថ្លែងការណ៍អ.ស.បស្តីពីការលុបបំបាត់អំពើហឹង្សាមកលើស្ត្រីដែលបាន អនុម័តនៅចុងឆ្នាំ ១៩៩៣ ក៏គួរតែកត់សំគាល់ផងដែរនៅក្នុងបរិបទនេះ។ នៅទីបំផុត សេចក្តីថ្លែងការណ៍ នេះថ្កោលទោសអំពើហឹង្សាខាងយេនឌ័រថាជាឧបសគ្គចំពោះសន្តិភាព យូរអង្វែង និងធ្វើការទិទៀនដោយចំហចំពោះអំពើហឹង្សាមកលើស្ត្រីនៅក្នុង សង្គ្រាម។ នៅឆ្នាំ ១៩៩៤ អ.ស.ប បានតែងតាំងអ្នកនាំពាក្យពិសេសស្តីពីអំពើហឹង្សាមកលើ ស្ត្រី ដែលចាប់តាំងពីពេលនោះមក បានចងក្រងអំពីអំពើហឹង្សាខាងយេនឌ័រនៅក្នុងប្រទេសជាច្រើនបន្ទាប់ពីបានឆ្លងកាត់សង្គ្រាម។

សាលាក្តី ICTY និង ICTR បានរួមបញ្ចូលអំពើហឹង្សាមកលើបុរស

សាលាក្តី ICTY និង ICTR បានបង្កើតលក្ខខណ្ឌច្បាប់ដំបូងពុំធ្លាប់មានពីមុនមកសម្រាប់ ការកាត់ទោសពីសំណាក់សហគមន៍អន្តរជាតិមកលើឧក្រិដ្ឋជននៃអំពើហឹង្សាខាង ផ្លូវភេទដែលទាក់ទងនឹងសង្គ្រាម។ សាលាក្តីទាំងពីរនេះបានឲ្យនិយមន័យអំពើរំលោភ និងការវាយប្រហារមកលើស្វ័យភាពខាងផ្លូវភេទ ជាឧក្រិដ្ឋកម្មដោយឡែកមួយ។ អំពើហឹង្សា មកលើបុរសត្រូវបានរួមបញ្ចូលយ៉ាងច្បាស់លាស់នៅទីនេះ។

ក្នុងចំណោមការចោទប្រកាន់ ៤៧៦ករណី នៅក្នុងសាលាក្តី ICTY ឧក្រិដ្ឋកម្មចំនួន 64 ករណីមានទាក់ទងនឹងអំពើហិង្សាខាងផ្លូវភេទមកលើស្ត្រី និង ៣១ករណីមកលើបុរស និង ៥ករណីដែលមានទាំងស្ត្រី និងបុរស ជាជនរងគ្រោះ។ ស្ត្រីគឺជាជនរងគ្រោះនៅក្នុងបណ្តឹងរំលោភចំនួន ១៩ករណី និងបុរសនៅក្នុង ៤ករណី។ នៅក្នុងករណីជាច្រើន មេបញ្ជាការសែរប៊ី បានបង្ខំបុរសជាប់ឃុំក្នុងពន្ធនាគារឲ្យរំលោភបំពានខាងផ្លូវភេទលើអ្នកទោសដទៃទៀត។ ទាំងសាធារណជនទូទៅ ឬ របាយការណ៍របស់អ្នកសារព័ត៌មានពុំបានចាប់អារម្មណ៍អំពីអំពើហិង្សាទាំងនេះឡើយ។ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបានផ្តោតតែលើស្ត្រីប្រមាណ ២០.០០០នាក់ដែលរងការរំលោភ។ ការប៉ាន់ស្មានខ្លះបានអះអាងថា មានអំពើឧក្រិដ្ឋកម្មបែបនេះរវាង ១២.០០០ និង៥០.០០០ករណី។ នៅក្នុងបណ្តាឆ្នាំបន្ទាប់មក ស្ត្រីអ្នកស្រាវជ្រាវខាងយេនឌ័របានពិភាក្សាអំពីការដាក់ បន្ទុករវាងអំពើហឹង្សាខាងផ្លូវភេទ និងទិដ្ឋភាពនៃអំណាចនៅក្នុងទំនាក់ទំនងខាង យេនឌ័រ ក៏ដូចជាក្នុងសង្គមផងដែរ។ ពួកគេបាន ពិចារណាអំពីលក្ខណៈរូបជីវសាស្ត្រ និងសង្គមសាស្ត្រ នៃយេនឌ័រ ក៏ដូចជា ការពាក់ព័ន្ធនៃទិដ្ឋភាពទាំងនេះជាមួយ ភាពខុសគ្នាខាងជាតិពន្ធុ និងសាសនាផងដែរ។ នៅទីបំផុត ស្ត្រី និងបុរសមូស្លីមនៅបូស្នៀរបានរងការរំលោភបំពានដោយសារពួកគេស្ថិតនៅក្នុងសហគមន៍ជនជាតិ និងសាសនាខុសគ្នា។ អ្នកដែលបានសង្កេតការណ៍នៅក្នុងសាលាក្តី បានលើកឡើងនូវ ការរិះគន់ចំពោះនីតិវិធិរបស់សាលាក្តី ICTY ដែលមូលដ្ឋានចំបងបំផុតនៃការជំទាស់របស់ពួកគេគឺថា ស្ត្រីជាសាក្សីមួយចំនួន មិនត្រូវបានសាកសួរអំពីប្រការនានាដែលទាក់ទងនឹងយេនឌ័រដូចមានចែងនៅក្នុងគោលការណ៍ណែនាំឡើយ។ ក្នុងករណីខ្លះស្ត្រីរងគ្រោះ/សាក្សី ត្រូវបានផ្ទៀងផ្ទាត់តាមរយៈការសួរចុងចោទ ដោយគ្មានការត្រៀមលក្ខណៈសម្រាប់ការធ្វើបែបនេះជាមុនផងទេ។ ស្ត្រីចៅក្រម និងប្រធានអយ្យការស្ថិតក្នុងក្រុមជនភាគតិច សូម្បីតែស្ត្រីជាសកម្មជនសិទ្ធិនារី បានរំពឹងចង់ឃើញអ្នកទាំងនេះមានឥរិយាបថផ្សេងពីនោះ ដោយចង់ឲ្យមានការគាំទ្រ និងមានការអាណិតអាសូរចំពោះស្ត្រីរងគ្រោះ/សាក្សីនៃអំពើហិង្សាក្នុងនាមជាមនុស្សដែលមានភេទដូចគ្នាផងដែរ។ បញ្ហានៅក្នុងសាលាក្តី ICTY មានការកែប្រែ នៅពេលដែល ប៉ាទ្រីស្យា វ៉ាសី-សែលីដែលជាមេធាវីប្រកបដោយបទពិសោធន៍ ត្រូវបានតែងតាំងជាទីប្រឹក្សាអមប្រធានអយ្យការសម្រាប់ឧក្រិដ្ឋកម្មហិង្សាខាងយេនឌ័រ។

សាលាក្តី ICTR ក៏តម្រូវឲ្យស្ត្រីជាជនដៃដល់ទទួលខុសត្រូវផងដែរ

នៅក្នុងសាលាក្តី ICTR ដែលមកទល់ពេលនេះបានកាត់ក្តីច្រើនជាង ៥០លើកមកហើយនោះ និងបានដាក់ទោសចុងចោទចំនួន២៩នាក់ លោកស្រីចៅក្រម

ណាវ៉ាំនេថេម ពីលេយ បានធ្វើឲ្យប្រាកដថា ចុងចោទម្នាក់ (ជីន ប៉ូល អាកាយេស៊ូ) ត្រូវបានកាត់ទោសដោយសារបទរំលោភ។ លោកស្រីបានប្រើប្រាស់និយមន័យធំទូលាយសម្រាប់ពាក្យរំលោភ ដែលក៏ពាក់ព័ន្ធផងដែរនៅក្នុងករណីនានាផ្សេងទៀតនៅពេលក្រោយមក។ មានធាតុផ្សំថ្មីៗផ្សេងទៀតនៅក្នុងនីតិវិធីរបស់សាលាក្តី ICTR៖ ស្រ្តីមិនត្រឹមតែអាចជាជនរងគ្រោះប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវបាននាំមករកយុត្តិធម៌ក្នុងនាមជាជនដៃដល់ផងដែរ ដូចជា អតីតនាយករដ្ឋមន្ត្រីវ៉ាន់ដា និងដូនជីកាតូលីកមួយចំនួន។ ទោះជាបែបនេះក៏ដោយ ស្រ្តីអ្នកស្រាវជ្រាវខ្លះបានទិទៀនប្រការដែលថា សាលាក្តីនេះបានយកចិត្តទុកដាក់គ្រប់គ្រាន់លើចំណងទាក់ទងអន្តរវិស័យរវាងយេនឌ័រ និងសញ្ញាណ នៃអំពើហឹង្សាខាងជាតិពន្ធុ និងការរើសអើងខាងពូជសាសន៍ឡើយ។ នៅទីបំផុត ស្រ្តីជាតិទុតស៊ី ត្រូវបានរំលោភ ដោយពួកគេអះអាងថា ដោយសារតែពួកគេជាតំណាងឲ្យ"ជាតិពន្ធុ"ណាមួយ ដែលកើតចេញពីប្រវត្តិអាណានិគមលើប្រទេសនេះ និងដោយសារតែពួកគេត្រូវបានចាត់ទុកថាមានអត្តសញ្ញាណអវិជ្ជមានពោលគឺមានផ្ទត់គំនិតរើសអើងខាង ពូជសាសន៍និងការឃោសនាបែបរើសអើងខាងផ្លូវភេទ នៅក្នុងប្រព័ន្ធព័ត៌មាននៅមុន និងក្រោយរបបប្រល័យពូជសាសន៍នោះ។ ការជម្រះក្តី ក៏ដូចជា ការប្រកាសសាលក្រមនានាដែលបានធ្វើឡើងនៅក្នុងសាលាក្តី ICTY និង ICTR ពិតជាបានផ្តួចផ្តើមឲ្យមានគំរូមួយនៃការកែប្រែនៅក្នុងយុត្តិសាស្ត្រ និងនយោបាយអន្តរជាតិ សូម្បីមិនបានគិតគូរយេនឌ័រពេញលេញក៏ដោយ៖ បើផ្អែកលើគោលការណ៍ សាលាក្តីទាំងពីរនេះបានចាត់ទុកអំពើឃោរឃៅនានាខាង យេនឌ័រ ស្មើនឹងអំពើនៃបទរំលោភដែលបានប្រព្រឹត្តមក លើស្រ្តី។ ទោះបីការវាយប្រហារខាងផ្លូវភេទមកលើបុរសត្រូវបាននាំមកកាត់ទោសក៏ដោយ អំពើហឹង្សាលើភេទដូចគ្នាច្រើន តែកើតឡើងដោយគ្មានការយកចិត្តទុកដាក់។ ឧក្រិដ្ឋកម្មជាក់លាក់មួយចំនួនទៀតត្រូវបានមើលរម្លង។ លើសពីនេះ អ្នករិះគន់បានបន្ទោសភាពដាច់ស្រយាលនៃសង្គមនានានៅសម័យក្រោយមានជម្លោះ ដោយអះអាងថា ពួកគេមិនបានទទួលដំណឹងគ្រប់គ្រាន់អំពីការងារដែលបានធ្វើនៅក្នុងសាលាក្តីនោះឡើយ។

ស្រ្តីមេធាវីមួយចំនួនដែលយកចិត្តទុកដាក់ក្នុងរឿងនេះបានសន្មតថា កង្វះការយកចិត្តទុកដាក់ជាបន្តបន្ទាប់ លើបញ្ហាយេនឌ័រ មានប្រភពនៅក្នុងការអះអាងរបស់បុរសថាខ្លួនជាភេទដែលមានសមត្ថភាព និងអំណាចលើសលុបរបស់បុរសនៅក្នុងស្ថាប័ន អន្តរជាតិដែលមានភារៈទទួលខុសត្រូវក្នុងការអនុម័ត និងអនុវត្តនិយាមខាងផ្នែកច្បាប់ ក៏ដូចជាលើនីតិវិធីព្រហ្មទណ្ឌផងដែរ។ ស្រ្តីអ្នកជំនាញការខាងច្បាប់ខ្លះទិទៀនថា ការផ្តោតដាច់ខាត ឬ ជាចំបងតែលើអំពើហឹង្សាខាងផ្លូវភេទដែលទាក់ទងនឹងសង្គ្រាម បានមើលរម្លងឋានានុក្រមយេនឌ័រដ៏ស្មុគស្មាញ និងរចនាសម្ព័ន្ធនៃអំពើហឹង្សានៅមុននិងក្រោយសង្គ្រាម។

ពួកគេក៏បានអះអាងផងដែរថា ព្រឹត្តិការណ៍នានាដែលបានកើតឡើងនៅក្នុងសង្គ្រាម ត្រូវបានបង្ក្រាបដោយអតីតយុទ្ធនារី ដូចជា នៅក្នុងករណីជាច្រើនស្ត្រីគឺជាជនដែដល់ និងក៏ជាជនរងគ្រោះផងដែរ ដោយបន្ថែមថា មូលដ្ឋានសម្រាប់ការបន្សុំយេនឌ័រឲ្យបានត្រឹមត្រូវឡើងវិញនៅក្នុងប្រព័ន្ធច្បាប់ក្នុងសង្គមនៅក្រោយសម័យសង្គ្រាមត្រូវបានបង្កើតឡើងត្រឹមកម្រិតកំណត់តែប៉ុណ្ណោះ។ ប្រការនេះជាប់ពាក់ព័ន្ធដូចជា តាមរយៈការបន្តមរតក អាពាហ៍ពិពាហ៍ និងកំណែទម្រង់ច្បាប់ស្តីពីដីធ្លី។ ស្របជាមួយសាលាក្តី ICTY និង ICTR ក៏មានសេចក្តីសម្រេចនានាផ្សេងទៀតផងដែរដែលបានធ្វើឡើងនៅកម្រិតអន្តរជាតិដែលប្រើជានិយាម ដើម្បីបិទបាំងអំពើហឹង្សាខាងយេនឌ័រដែលទាក់ទងនឹងសង្គ្រាម។ សេចក្តីព្រាងឯកសារសម្រេចនៅឆ្នាំ ១៩៩៥ សម្រាប់សន្និសីទពិភពលោកស្តីពីស្ត្រី ដែលបានធ្វើនៅទីក្រុងប៉េកាំង និងផែនការសកម្មភាពដែលបានអនុម័តនៅទីនោះ បានញែកភាពខុសគ្នារវាងទម្រង់ដោយឡែកនានានៃអំពើហឹង្សាខាងយេនឌ័រ និងបានថ្កោលទោសដោយចំហរចំពោះអំពើហឹង្សាខាងផ្លូវភេទ ដែលបានប្រព្រឹត្តនៅក្នុងសង្គ្រាម។ ឯកសារចងក្រងអំពីការទាមទារនានា រួមមានបណ្តឹងព្រហ្មទណ្ឌចំពោះជនដែដល់និងយុទ្ធសាស្ត្រនានាដែលបានបង្កើតឡើងដើម្បីទប់ស្កាត់អំពើហឹង្សាខាងយេនឌ័រ។

៣.១.២ តុលាការព្រហ្មទណ្ឌអន្តរជាតិ និងយេនឌ័រ

តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) នៅទីក្រុងឡាអេ ត្រូវបានបង្កើតក្នុងឆ្នាំ ១៩៩៨ ផ្អែកតាមលក្ខន្តិកៈក្រុងរ៉ូម។ នៅក្នុងករណីនេះ រដ្ឋដែលបានចុះហត្ថលេខាលើលក្ខន្តិកៈនេះបានបង្កើតមូលដ្ឋានគ្រឹះសម្រាប់បណ្តឹងព្រហ្មទណ្ឌលើឧក្រិដ្ឋកម្មសង្គ្រាមអំពើប្រល័យពូជសាស្ត្រ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ តុលាការ ICC មានភារៈទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែល កើតឡើងនៅក្នុងដែនដីនៃប្រទេសជាហត្ថលេខី ឬ ដែលបានប្រព្រឹត្តដោយពលរដ្ឋនៃប្រទេស ហត្ថលេខី។ តុលាការនេះចូលរួមតែនៅក្នុងករណីដែលតុលាការនៅក្នុងប្រទេសដែល ពាក់ព័ន្ធនោះអស់លទ្ធភាពក្នុងការនាំខ្លួនជនប្រព្រឹត្តិណាម្នាក់មកកាត់ទោស។ ទោះជាយ៉ាងណាក៏ដោយក្រុមប្រឹក្សាសន្តិសុខនៃអ.ស.ប មានសិទ្ធិក្នុងការបញ្ជូនករណីពិសេសដោយ ផ្ទាល់ទៅតុលាការនេះ។ នៅក្នុងសង្គមក្រោយសម័យសង្គ្រាម ជាញឹកញាប់ បណ្តឹងព្រហ្មទណ្ឌមិនអាចធ្វើទៅបានឡើយ ដោយសារប្រព័ន្ធយុត្តិធម៌របស់ជាតិពុំដំណើរការ។ ក្នុងកន្លែងជាច្រើន មធ្យោបាយនៃច្បាប់បានក្លាយជាផ្នែកមួយនៃរបបផ្តាច់ការ និងពុំអាចធានាភាពគ្មានលំអៀងឡើយនៅមុនពេលកើតសង្គ្រាម។អាស្រ័យហេតុនេះ អ្នកជំនាញការច្បាប់ខ្លះស្នើឲ្យសហគមន៍អន្តរជាតិមានភារៈកិច្ចចូលធ្វើអន្តរាគមន៍។ ជំហរនេះគឺជាប្រធានបទមួយនៃការជជែកតានតឹង តានតឹង ជាពិសេស ដោយសារប្រទេសមហាអំណាចដូចជា ស.រ.អា ពុំបានចុះហត្ថលេខាលើលក្ខន្តិកៈក្រុងរ៉ូមនៅឡើយទេ។

ដូច្នេះ ឧក្រិដ្ឋជនសង្គ្រាមពីស.រ.អា មិនអាចចោទប្រកាន់ដោយតុលាការ ICCបានឡើយ។ មកទល់ពេលនេះ តុលាការ ICC ច្រើនតែបានធ្វើការស៊ើបអង្កេតឧក្រិដ្ឋជនសង្គ្រាម ពីណ្តាប្រទេសនៅអាហ្វ្រិក ទៅតាមការស្នើសុំរបស់រដ្ឋាភិបាលនៃប្រទេសទាំងនោះ តែ ប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ នេះជាកិច្ចការដ៏តានតឹងនៅក្នុងសហភាព អាហ្វ្រិក។ អង្គការសិទ្ធិស្ត្រីនិងសិទ្ធិមនុស្សនៅអាហ្វ្រិកកំពុងរារាំងការប៉ុនប៉ងរបស់សមាជិកខ្លះនៅក្នុងសហភាពអាហ្វ្រិកក្នុងការដកហូតលក្ខខន្តិកៈក្រុងរ៉ូមមកវិញ។23

លក្ខន្តិកៈក្រុងរ៉ូមរួមបញ្ចូលគោលការណ៍ណែនាំនានាសម្រាប់ជនរងគ្រោះនៃអំពើហឹង្សាខាងផ្លូវភេទ

ទាក់ទងនឹងទិដ្ឋភាពយេនឌ័រ លក្ខន្តិកៈក្រុងរ៉ូមអនុញ្ញាតឲ្យតុលាការ ICC វិនិច្ឆ័យករណីនានានៃឧក្រិដ្ឋកម្មខាងផ្លូវភេទដែលទាក់ទងនឹងសង្គ្រាម (បទរំលោភ ទាសភាពខាងផ្លូវភេទ ពេស្យាចារ្យដោយបង្ខំ ការបង្ខំឲ្យមានផ្ទៃពោះ ការបង្ខំឲ្យបំបាត់លទ្ធភាពបន្តពូជ) ជាឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិ។ ការជួញដូរស្ត្រីក៏អាចបន្ថែមទៅក្នុងបន្ទុកជាឧក្រិដ្ឋកម្មផងដែរ។ លក្ខន្តិកៈក្រុងរ៉ូមបែងចែកភាពខុសគ្នារវាងអំពើហឹង្សា ខាង ផ្លូវភេទ និងហឹង្សាខាងយេនឌ័រ។ ភាពខុសគ្នាបានផ្អែកលើយេនឌ័រជារចនា សម្ព័ន្ធសង្គម ស្របតាមបទបញ្ញា និងនីតិវិធីរបស់អ.ស.ប និងយោងជាពិសេសទៅប្រយោគនៅក្នុងវេទិកាសកម្មភាពក្រុងប៉េកាំង។ ក្នុងន័យនេះ វាជាការលំបាកសម្រាប់យុត្តិធម៌ អន្តរជាតិ ដើម្បីកំណត់ភាពស្មុគស្មាញនៃទំនាក់ទំនងគ្នារវាងទម្រង់ទាំងនេះនៃអំពើហឹង្សា។ បញ្ហាបន្ថែមទៀតពាក់ព័ន្ធនឹងប្រការដែលថា វេទិកាសកម្មភាពក្រុងប៉េកាំង សង្កត់ធ្ងន់តែលើអត្តសញ្ញាណយេនឌ័របុរស និងស្ត្រី និងមិនចែងអំពីអត្តសញ្ញាណនៃអ្នកដែលមាននិន្នាការស្រឡាញ់ភេទដូចគ្នា ឬអត្តសញ្ញាណ/និន្នាការផ្សេងខាងផ្លូវភេទ។ ក្រុមទាំងនេះក៏មិនបានទទួលការពិចារណានៅក្នុងលក្ខន្តិកៈក្រុងរ៉ូមផងទេ។

លក្ខន្តិកៈនេះមានគោលការណ៍ណែនាំមិនត្រឹមតែសម្រាប់ការស៊ើបអង្កេតរបស់តុលាការប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់ការជំរះក្តីផងដែរ៖ ជនរងគ្រោះ និងសាក្សីមានសិទ្ធិក្នុងការផ្តល់សក្ខីកម្មនៅក្នុងនីតិវិធីតុលាការដែលមិនបើកចំហជាសាធារណៈ ដើម្បីរក្សាការសម្ងាត់ជាឯកជនរបស់ពួកគេ។ ពួកគេគួរតែបានទទួលការគាំទ្រពីអ្នកជំនាញការខាងផ្លូវចិត្តដែលអាចចូលរួមនៅក្នុងសវនាការ និងទទួលការទូទាត់សម្រាប់ការពាក់ព័ន្ធរបស់ពួកគេ។ លើសពីនេះ មូលនិធិត្រឹះក៏បានបង្កើតឡើងផងដែរ ដើម្បីជួយពួកគេ។ ក្នុងករណីធ្វើបាន អត្តសញ្ញាណរបស់សាក្សីនឹងត្រូវរក្សាជាសម្ងាត់នៅពេលចងក្រងករណីនេះ ដោយរក្សាឈ្មោះជាអនាមិក។

ជនរងគ្រោះពីអំពើហឹង្សាខាងផ្លូវភេទ ពុំជាប់កាតព្វកិច្ចដើម្បីចូលរួមយ៉ាងសកម្មនៅក្នុងការផ្តល់ភស្តុតាងឡើយ។ ចៅក្រមត្រូវរៀបចំសំណួរចំពោះ សាក្សី និង/ឬជនរងគ្រោះអំពីអំពើហឹង្សាខាងផ្លូវភេទ តាមវិធីដែលមិនបំភិតបំភ័យ ឬដែលអាចឲ្យមានភាពតក់ស្លុតឡើយ។ ការតែងតាំងចៅក្រម និងអយ្យការ/មេធាវី ត្រូវតែមានតំណាងសមស្របជាស្ត្រី និងបុរស។ ពួកគេគួរតែមានទីប្រឹក្សាខាងច្បាប់សម្រាប់ជួយនៅក្នុងកិច្ចការដែលទាក់ទងនឹងអំពើហឹង្សាខាងយេនឌ័រ។

ចំណុចរិះគន់៖ ស្ត្រីជាសាក្សីបានទទួលព័ត៌មាន និងកិច្ចការពារគ្រប់គ្រាន់

ទោះជាយ៉ាងណាក៏ដោយ គោលការណ៍ណែនាំខុសៗគ្នាទាំងនេះនៃលក្ខន្តិកៈ ក្រុងរ៉ូមត្រូវបានអនុវត្តជាក់ស្តែងក្នុងកម្រិតកំណត់តែប៉ុណ្ណោះ ដែលធ្វើឲ្យមានការតវ៉ាពីអ្នករិះគន់នានា។ ស្ត្រីជាសាក្សីមិនបានទទួលព័ត៌មានគ្រប់គ្រាន់អំពីសិទ្ធិរបស់ខ្លួន ឬដំណើរការនៅក្នុងសវនការឡើយ។ វាក្យស័ព្ទខាងផ្នែកច្បាប់ ត្រូវបានអ្នករិះគន់ពោលថាគឺជាការរារាំងស្ត្រីពីការផ្តល់សក្ខីកម្មអំពីការរំលោភ តាមទម្រង់ដែលអាចឲ្យចម្លើយរបស់ពួកគេយកជាការបាននៅក្នុងសវនាការ និងបន្ថែមថា លក្ខខណ្ឌតឹងតែងនៅក្នុងសវនាករច្រើនតែមិនផ្តល់ឱកាសឲ្យស្ត្រីជាជនរងគ្រោះ/សាក្សីក្នុងការរម្លឹកឡើងវិញនូវការចងចាំរបស់ខ្លួនអំពីព្រឹត្តិការណ៍ដែលកើតឡើងឡើយ ពោលគឺ ការកំណត់បរិបទនៃអំពើហឹង្សាដែលខ្លួនបានឆ្លងកាត់។ ស្ត្រីដែលជាអ្នករួចជីវិតនៅក្នុងអំពើហឹង្សាខាងផ្លូវភេទត្រូវបានចាត់ទុកត្រឹមតែជាជនរងគ្រោះធម្មតាប៉ុណ្ណោះនៅក្នុងសវនាការ និងមិនបានទទួលស្គាល់ថាជាអ្នករួចជីវិតទៅតាមខ្លឹមសារនៃការទាមទាររបស់ស្ត្រី ហើយបើយោងតាមអ្នករិះគន់ដែលបានបន្ថែមថា ស្ត្រីមិនសុទ្ធតែប្រាកដថាត្រូវរួមបញ្ចូលនៅក្នុងកម្មវិធីការពារស្ត្រីជាសាក្សីឡើយ។ អ្នកទាំងនោះមួយចំនួនបានរងការមាក់ងាយ និងឈឺចាប់ដោយសារការបំពានសារជាថ្មីនៅពេលវិលត្រឡប់មកសហាគមន៍វិញ។

នៅក្នុងការប៉ាន់ស្មានរបស់អ្នករិះគន់ ជួនកាល ការដាក់បន្ទុកមិនធ្ងន់ធ្ងរសមស្របឡើយ៖ នៅក្នុងការជំរះក្តីខ្លះ ចំពោះឈ្មួញសង្គ្រាមនៅកុងហ្គោ និងមេដឹកនាំទ័ពព្រៃ ពួកគេបានអះអាងថា ការចាប់បង្ខំកុមារឲ្យចូលធ្វើទាហានត្រូវបានសើបអង្កេត ប៉ុន្តែមិនបានផ្អែកលើមូលដ្ឋាននៃអំពើហឹង្សាខាងផ្លូវភេទឡើយ សូម្បីនេះជាផ្នែកមួយនៃបច្ចេកទេសដែលប្រើប្រាស់ដើម្បីកេណ្ឌកុមារី និងរចនាសម្ព័ន្ធអំណាចដែលនិយមប្រើនៅក្នុងអង្គភាពនានាក៏ដោយ។ អតីតប្រធានអយ្យការនៅក្នុងតុលាការ ICC បានអះអាងថា វាជាការលំបាកក្នុងការបញ្ជាក់អំពីការបំពារបំពាន ដោយផ្អែកលើសក្ខីកម្មរបស់សាក្សី។ យោងតាមអ្នករិះគន់ ឱកាសនានាត្រូវបាត់បង់ ក្នុងការបង្កើតលក្ខខណ្ឌនាំមុខសម្រាប់ប្តឹងឧក្រិដ្ឋជននៃអំពើហឹង្សាខាងផ្លូវភេទ។ មានតែមួយករណីដែលជាការរំលោភកុមារា និងបុរស ដែលបានដាក់បន្ទុក។

ពេលវេលានឹងប្រាប់អំពីថាតើចំណុចនានានៃការរិះគន់នឹងអាចបំបាត់បាននៅក្នុងអាណត្តិនៃប្រធានអយ្យការថ្មីលោកស្រីហ្វាទូ បេនស៊ូដាដែលបានចូលកាន់តំណែងនៅឆ្នាំ ២០១២។ នៅក្នុងពេលស្បថចូលកាន់តំណែង លោកស្រី ប្រកាសយ៉ាងច្បាស់ថាបំណងរបស់លោកស្រីគឺជួយកុមារ និងស្ត្រីបានទទួលយុត្តិធម៌។ នៅចុងខែសីហា ឆ្នាំ ២០១២ លោកស្រីបានតែងតាំង ប្រ៊ីជីដ អ៊ីនដេ នាយកកិច្ចផ្តួចផ្តើមស្ត្រីដើម្បីយុត្តិធម៌យេនឌ័រជាទីប្រឹក្សាខាងយេនឌ័ររបស់គាត់។

កិច្ចផ្តួចផ្តើមស្ត្រីដើម្បីយុត្តិធម៌យេនឌ័រសម្រាប់សមភាពនៃតំណាងជាស្ត្រីនិងបុរសនៅក្នុងតុលាការ ICC

កិច្ចផ្តួចផ្តើមស្ត្រីដើម្បីយុត្តិធម៌យេនឌ័រ គឺជាផ្នែកមួយនៃសម្ព័ន្ធភាពដើម្បី តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលជាបណ្តាញមួយនៃអង្គការមិនមែនរដ្ឋាភិបាល ដែលតាមដានការងាររបស់តុលាការ ICC ក្នុងគោលដៅកែលម្អ។ កិច្ចផ្តួចផ្តើមស្ត្រីដើម្បីយុត្តិធម៌យេនឌ័រចែករម្លែក និងផ្លោះប្តូរទស្សនៈ និងបទពិសោធន៍ជាមួយអង្គការសិទ្ធិនារីជាតិនិងអន្តរជាតិនិងសន្តិភាព។ តាំងពីឆ្នាំ ២០០៥មក កិច្ចផ្តួចផ្តើមនេះបានសង្កេតនូវការ អភិវឌ្ឍខាងស្ថាប័ននៃតុលាការ ICC និងដំណើរការនានានៃតុលាការនេះ។ ផ្អែក តាមការងារបញ្ចុះបញ្ចូលដល់គណៈកម្មការស្ត្រីដើម្បីយុត្តិធម៌យេនឌ័រ ស្ត្រីជាអ្នកជំនាញការខាងសិទ្ធិនារីបានបង្កើតកិច្ចផ្តួចផ្តើមនេះនៅក្នុងពេលបង្កើតលក្ខន្តិកៈក្រុងរ៉ូមនិងពេលបង្កើតតុលាការ ICC។ កិច្ចផ្តួចផ្តើម ស្ត្រីដើម្បីយុត្តិធម៌យេនឌ័រផ្តល់វគ្គបណ្តុះបណ្តាលអំពីយេនឌ័រ និងបានប្រមូលឯកសារណែនាំដែលផ្អែកលើការ អនុវត្តជាក់ស្តែង។ ក្នុងចំណោមកិច្ចការ ផ្សេងទៀតជាច្រើន កិច្ចផ្តួចផ្តើមនេះបានអំពាវនាវឲ្យមានចំនួនស្មើគ្នានៃមេធាវីជា ស្ត្រី និងបុរស សម្រាប់ការតែងតាំងជាចៅក្រមក្នុងតុលាការ ICC និងមជ្ឈមណ្ឌលផ្តល់ យោបល់ខាងផ្នែកច្បាប់ ក៏ដូចជាកម្មវិធីការពារស្ត្រីជាសាក្សី ដែលត្រូវបង្កើតឡើងនោះផងដែរ។ កិច្ចផ្តួចផ្តើមនេះបានចេញផ្សាយប័ណ្ណរាយការណ៍ ពិស្តារអំពីយេនឌ័រប្រចាំឆ្នាំ ដែលមានការវិភាគជាក់លាក់អំពីយេឌ័រនៃការអភិវឌ្ឍស្ថាប័ន រចនាសម្ព័ន្ធបុគ្គលិក និងដំណើរការ និង/ឬការដាក់បន្ទុក។

របាយការណ៍ពិស្តារទាំងនេះក៏បង្ហាញពីការងារផ្សព្វផ្សាយនៅក្នុងប្រទេសនានាដែលមានជម្លោះ និងលើកអនុសាសន៍សម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិផងដែរ។ នៅឆ្នាំ ២០១១ និង ២០១២ កិច្ចផ្តួចផ្តើមស្ត្រីដើម្បីយុត្តិធម៌យេនឌ័របានធ្វើការរិះគន់ ដូចជា ការកាត់បន្ថយយ៉ាងច្រើននូវចំនួនបុគ្គលិក និងមូលនិធិសម្រាប់ការងារផ្សព្វផ្សាយ។ កិច្ចផ្តួចផ្តើមនេះអះអាងថា ជាលទ្ធផល ស្ត្រីនៅទីជនបទ ដែលស្ថិតក្រោមការស៊ើបអង្កេតរបស់តុលាការ ICC នឹងពុំបានទទួលព័ត៌មានគ្រប់គ្រាន់ឡើយ

ហើយការងារអប់រំនិងព័ត៌មានបែបនេះមានសារៈសំខាន់ណាស់សម្រាប់ធ្វើការជាមួយសាក្សី ក៏ដូចជា តម្លាភាព និងការទទួលយក ICC នៅតាមមូលដ្ឋានផងដែរ។ អ្នកវិទ្យាសាស្ត្រនានាបានផ្ទៀងផ្ទាត់ប្រការនេះ ដោយផ្អែកលើការសិក្សាបែបពិសោធន៍របស់ពួកគេ។

៣.១.៣ តុលាការកូនកាត់ - ករណីសិក្សា៖ តុលាការពិសេសសេរ៉ាលេអូន (SCSL)

តុលាការពិសេសសេរ៉ាលេអូន (SCSL) គឺជាឧទាហរណ៍ដំបូងមួយនៃតុលាការកូនកាត់។ តុលាការនេះបានបង្កើតឡើងដោយអ.ស.ប ក្រោមកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលសេរ៉ាលេអូន។ ទាំងចៅក្រមជាតិ និងអន្តរជាតិត្រូវបានតែងតាំងសម្រាប់តុលាការនេះ។ សេចក្តីសម្រេចរបស់អ.ស.ប លេខ ១៣១៥ ចុះថ្ងៃទី ១៤ ខែសីហាឆ្នាំ ២០០០ បានកំណត់ថា តុលាការពិសេសឯករាជ្យត្រូវតែង្កើតឡើងដើម្បី សើបអង្កេតឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ដែលបានប្រព្រឹត្ត នៅក្នុងអំឡុងពេលសង្គ្រាមស៊ីវិល ជាពិសេសចាប់ផ្តើមពីថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៦ ដែលជាកាលបរិច្ឆេទនៃការចុះហត្ថលេខាលើកិច្ចព្រមព្រៀង សន្តិភាពក្រុងអាប៊ីដហ្សង់ និងការពង្រីករហូតដល់កិច្ចព្រមព្រៀងសន្តិភាពជាផ្លូវការនៅថ្ងៃទី ០៨ ខែមករា ឆ្នាំ ២០០២។ សង្គ្រាមស៊ីវិលឆ្លងដែននេះបានចាប់ផ្តើមនៅឆ្នាំ ១៩៩១។ អស់រយៈពេលច្រើនជាងមួយទសវត្សរ៍ និងដោយមានការគាំទ្រពីឈ្មួញសង្គ្រាម លីបេរី និងប្រធានាធិបតីនៅអាណត្តិក្រោយមកនៃប្រទេសលីបេរី លោក ឆាល ថៃល័រ រណៈសិរ្សឯកភាពបដិវត្ត (RUF) បាន ប្រយុទ្ធប្រឆាំងនឹងរដ្ឋាភិបាលខុសៗ គ្នា ដែលបានចូលមកកាន់អំណាច ក៏ដូចជាភាគីជម្លោះខុសៗគ្នាដទៃទៀតផងដែរ ដូចជា កងកម្លាំងការពារជនស៊ីវិល (CDF) នៅសេរ៉ាលេអូនផងដែរ។

តំណាងនានានៃ RUF និង CDF – ទោះបីមិនមែនជាសមាជិកនៃកម្លាំងប្រដាប់អាវុធសេរ៉ាលេអូនក៏ដោយ នៅទីបំផុតនៅតែមានដំណោះស្រាយសម្រាប់ SCSL។ ទោះបីជម្រើសភាគីទាំងនេះបានទទួលការរិះគន់នៅទូទាំងប្រទេសក៏ដោយ ប្រធានាធិបតីនៅពេលនោះ លោក អាម៉ាដ តេជ្សាន កាបា មានការចាប់អារម្មណ៍ជាពិសេសលើការប្តឹងតំណាងនានាក្នុងតំណែងជាន់ខ្ពស់នៃ RUF និង CDF។ ទោះបីបានបង្កើតតុលាការនេះនៅក្នុងទីក្រុងហ្វ្រីថោនហើយក៏ដោយ ប្រជាជនជាច្រើនមិនអាចតាមដានឲ្យដឹងថាតុលាការនេះអាចធានាយុត្តិធម៌ដែរឬទេ៖ នាយកដ្ឋានទំនាក់ទំនងសាធារណៈនៃប្រទេសនេះ ក៏ដូចជា ប្រព័ន្ធផ្សាយព័ត៌មានជាតិ និងអន្តរជាតិបានធ្វើសេចក្តីរាយការណ៍តិចតួចប៉ុណ្ណោះអំពីការជំរះក្តីនីមួយៗ។ តុលាការពិសេសនេះបានពិចារណាត្រឹមតិចតួច ឬគ្មានសោះអំពីអំពើហឹង្សាខាងយេនឌ័រ ដែល ការសម្រេចភាគច្រើនទាក់ទងនឹងឥរិយាបថដែលចៅក្រមប្រកាន់យក។

តុលាការនេះមានឈ្មោះអាក្រក់នៅក្នុងដើមឆ្នាំ ២០០៥ ក្នុងពេលដែលប្រធានអយ្យការ លោក ភីធ័រ ហាល័រ ត្រូវបានរកឃើញថាមានទោសពីបទបំពានលើកុមារីអាយុ ដប់បីឆ្នាំ និង ត្រូវបានកាត់ទោសជាប់ពន្ធនាគារដប់ប្រាំបីខែ។

ទុកការរិះគន់មួយឡែក- តុលាការ SCSL បង្កើតស្តង់ដារថ្មីនៅក្នុងការជំរះក្តីករណីលោកថាយល័រ

អតីតប្រធានាធិបតីប្រទេសលីបេរី ឆាល ថាយល័រ ក៏ត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនចំពោះមុខតុលាការ ពិសេស សេរ៉ាលេអូន ក្នុងនាមជាអតីតឈ្មួញសង្គ្រាម និងជនស្រេកឃ្លានសង្គ្រាម។ ថាយល័រ បានក្លាយជាជនសំខាន់ម្នាក់នៅក្នុងសង្គ្រាមស៊ីវិលនៅសេរ៉ាលេអូន និងជាអ្នកផ្តល់ថវិកាដល់ RUF។ គាត់ត្រូវបានទម្លាក់ចេញពីតំណែងដោយ SCSL នៅឆ្នាំ ២០០៣ និងត្រូវបានឃុំខ្លួននៅឆ្នាំ ២០០៦។ ថាយល័រជាប់ បណ្តឹងករណីអាពាហ៍ពិពាហ៍ដោយបង្ខំជាលក្ខណៈប្រព័ន្ធ ទាសភាពខាងផ្លូវភេទ និងការរំលោភដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងចំណោមករណីដទៃទៀត។ ដើម្បី ទប់ស្កាត់អស្ថិរភាពនយោបាយណាមួយនៅសេរ៉ាលេអូន ការជំរះក្តីបានធ្វើនៅទីក្រុងឡាអេ។ នៅថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០១២ ឆាល ថាយល័រត្រូវបានរកឃើញថាមានកំហុសនៅក្នុងគ្រប់ករណីបណ្តឹងទាំង ១១ នៅក្នុងតុលាការពិសេសសេរ៉ាឡេអូន។ នេះជាការកត់សំគាល់ជាលើកដំបូងថា (អតីត)ប្រធានរដ្ឋ ជាមេបញ្ជាការ និងមិនមែនជាជនដៃដល់ផ្ទាល់ ក៏ត្រូវបានកាត់ទោសពីអំពើហឹង្សាខាងផ្លូវភេទផងដែរ។ នៅក្នុងពេលប្រហែលគ្នានោះ នៃការប្រកាសជាផ្លូវការសម្រាប់ការជំនុំជម្រះក្នុងតុលាការ SCSL គណៈកម្មការស្វែងរកការណ៍ពិត និងការផ្សះផ្សារ (TRC) នៅសេរ៉ាលេអូនបានចាប់ផ្តើមការងាររបស់ខ្លួន។ ទិដ្ឋភាពដោយឡែកមួយនៃការវិវត្តនៅក្នុងសម័យក្រោយសង្គ្រាមនៅក្នុងប្រព័ន្ធនយោបាយ និងយុត្តិធម៌នៅសេរ៉ាលេអូន គឺថា អំពើហឹង្សាខាងយេនឌ័រនៅតែបន្តរហូតដល់សព្វថ្ងៃនេះ ដោយរដ្ឋាភិបាលបានបង្ហាញពីកង្វះឆន្ទៈនយោបាយក្នុងការអនុវត្តកំណែទម្រង់ក្នុងវិស័យច្បាប់ និងសន្តិសុខ សូម្បីតែប្រទេសនេះជាប់កាតព្វកិច្ចដើម្បីលុបបំបាត់អំពើហឹង្សាមកលើស្ត្រី ទៅតាមផែនការសកម្មភាពស្តីពី សេចក្តីសម្រេចរបស់អ.ស.ប លេខ ១៣២៥ ក៏ដូចជា វិសោធនកម្មច្បាប់មួយចំនួនក៏ដោយ។ នេះជាការចង្អុលបង្ហាញអំពីឱកាសដែលបានកន្លងផុត ទាក់ទងនឹងការប្រកាសអំពើហឹង្សាខាងផ្លូវភេទជាបញ្ហាសង្គមនៅក្នុងអំឡុងពេលនៃការសម្រុះសម្រួលជាមួយ ឧក្រិដ្ឋកម្មសង្គ្រាម។ ប្រការនេះធ្វើឲ្យការកាត់ទោស ថាយល័រ នៅក្នុងតុលាការ SCSL រឹងរឹតតែមានសារៈសំខាន់សម្រាប់សកម្មភាពបញ្ចុះបញ្ចូលខាងនយោបាយ ដែលធ្វើឡើងដោយអង្គការមួយចំនួនតូច ដែលមានការប្តេជ្ញាខ្ពស់ខាងសិទ្ធិនារីនិងសិទ្ធិមនុស្ស។

៣.១.៤ តុលាការកូនកាត់ - ករណីសិក្សា៖ អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (ECCC)

បើគិតអំពីយេនឌ័រ តុលាការកូនកាត់មួយផ្សេងទៀតមានលក្ខណៈគួរឲ្យចាប់ អារម្មណ៍ ទាក់ទងនឹងការសម្រុះសម្រួលជាមួយអំពើរំលោភធ្ងន់ធ្ងរលើសិទ្ធិមនុស្ស៖ អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (ECCC)។ ផ្អែកតាមច្បាប់ដែលបានអនុម័តនៅ ឆ្នាំ ២០០១ និងបានធ្វើវិសោធនកម្មនៅឆ្នាំ ២០០៤ (ច្បាប់ ECCC) អ្នកទទួលខុសត្រូវជាបឋម ចំពោះឧក្រិដ្ឋកម្មឃោរឃៅនៅក្នុងរបបខ្មែរក្រហមនៅកម្ពុជា រវាងថ្ងៃទី ១៧ មេសា ឆ្នាំ ១៩៧៥ និង ៦ មករា ឆ្នាំ ១៩៧៩ ត្រូវនាំមកកាត់ទោសពីបទព្រហ្មទណ្ឌ។ ខ្មែរក្រហម គឺជាគណៈបក្សកុម្មុយនិស្តកម្ពុជា ដែលដឹកនាំដោយប៉ុលពត និងទទួលខុសត្រូវក្នុងការ ជម្លៀសដោយបង្ខំ ការបង្ខំឲ្យរស់នៅជាសមូហភាព ពលកម្មដោយបង្ខំនៅក្នុងវិស័យ កសិកម្ម អាពាហ៍ពិពាហ៍ដោយបង្ខំ ការបំបែកឪពុកម្ដាយពីកូន ការបង្ក្រាបជាទ្រង់ទ្រាយធំ ក៏ដូចជា ទារុណកម្ម និងការសម្លាប់"សត្រូវបដិវត្តន៍"ផងដែរ។ ការផ្ដោតលើ ចក្ខុវិស័យនៃប្រជាជនថ្មី បទបញ្ជាត្រូវបានអនុវត្តមកលើគ្រប់ទិដ្ឋភាពនៃ ជីវិតឯកជន និងកងកម្លាំងនានាដែលត្រូវបានដាក់ពង្រាយក្នុងគោលបំណង ធ្វើការត្រួតត្រា និងដាក់ទណ្ឌកម្ម។ វិធានការនានាអនុវត្តដោយរបបឃោធា ដែលមានរួមបញ្ចូលការ ពិសោធន៍វេជ្ជសាស្ត្រលើមនុស្ស អំពើហឹង្សាខាងផ្លូវភេទមកលើស្ត្រី និងបុរស ក៏ដូចជា ការរំលូតកូនដោយបង្ខំ បាននាំមកនូវភាពអត់ឃ្លាន ជម្ងឺ និងការបាត់បង់ជីវិតយ៉ាង ហោចណាស់មនុស្ស ១,៧លាននាក់។ ទាំងអ្នកប្រព្រឹត្ត និងជនរងគ្រោះនៃការរំលោភ ត្រូវដាក់ទណ្ឌកម្មពីសំណាក់ក្រុមទាំងនេះ ដោយសារតែ"ឧក្រិដ្ឋកម្មសីលធម៌"របស់ពួកគេ។ តុលាការប្រជាជនបដិវត្តន៍ មានវត្តមានតាំងពីឆ្នាំ ១៩៧៩ ប៉ុន្តែមិនបានចាត់បញ្ចូលអំពើ ហឹង្សាខាងយេនឌ័រឡើយ។ បន្ទាប់ពីមានការចរចាយ៉ាងយូរលើខ្លឹមសារនៃ ការកាត់ក្ដី និងថាតើ នីតិវិធីច្បាប់ណានឹងត្រូវយកមកអនុវត្ត នៅទីបំផុតតុលាការនេះបានចាប់ផ្ដើម ការងាររបស់ខ្លួននៅថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ ២០០៣។ តុលាការនេះមានចៅក្រមអន្តរជាតិ និងកម្ពុជាចំនួន ១៧រូប។ ចៅក្រមទាំងនេះធ្វើការស៊ើបអង្កេតអា ពាហ៍ពិពាហ៍ដោយបង្ខំ ដែល ស្ថិតក្រោមការបញ្ជាជាបន្តបន្ទាប់ពីរដ្ឋាភិបាល។ ការជជែកវែកញែកអំពីច្បាប់ និងវិទ្យាសាស្ត្រ មិនត្រឹមតែផ្ដោតលើថាតើស្ត្រីបានក្លាយជាជនរងគ្រោះដោយ របៀបណា ប៉ុណ្ណោះទេ ក៏ប៉ុន្តែចំពោះបុរសនៅក្នុង អាពាហ៍ពិពាហ៍បែបនេះផងដែរ។ នៅក្នុងករណីមួយ មេធាវីអាល្លីម៉ង់បានស៊ើបអង្កេតករណីអាពាហ៍ពិពាហ៍ដោយបង្ខំនៃ បុរស ដែលមានអត្តសញ្ញាណ ភេទមិនពិតប្រាកដម្នាក់។ នៅក្នុងសេវាសន្តិភាពស៊ីវិលរបស់ ខ្លួន លោកស្រីមេធាវីបានធ្វើការ ពិនិត្យមើលទិដ្ឋភាពនានាខាង យេនឌ័រនៅពេលធ្វើជា តំណាងឲ្យជនរងគ្រោះ។

ករណីពិសេស៖ ECCC បានគិតគូរអំពីប្រជាជនដែលមានអត្តសញ្ញាណយេនឌ័រខុសៗគ្នា

ទោះបីការផ្តោត ឬ មិនផ្តោតលើអាពាហ៍ពិពាហ៍ដោយបង្ខំ អាចជួយលុបបំបាត់អំពើហឹង្សាខាងយេនឌ័រ និងឋានានុក្រមយេនឌ័រ នៅជាចំណោទនៅឡើយក៏ដោយៈ សង្គមកម្ពុជាជឿថា ការផ្តោតបែបនេះមានសារៈសំខាន់បន្ទាប់បន្សំ ធៀបនឹងទម្រង់ដទៃទៀតនៃអំពើហឹង្សាជាទ្រង់ទ្រាយធំ។ ទស្សនៈទូទៅមួយផ្សេងទៀតគឺថា ខ្មែរក្រហមបានគោរពក្រមសីលធម៌មួយ។ អ្វីដែលមានបន្ថែមទៀត តុលាការខ្លួនឯងគឺជាប្រធានបទនៃជម្លោះ។ អំណាច និងដំណើរការនៃតុលាការនេះស្ថិតក្នុងការជជែកតានតឹងនិង/ឬ ត្រូវបានអ្នករិះគន់មើលឃើញថា ស្ថិតក្រោមគំនាប ដោយសារតែឥទ្ធិពលនយោបាយនៅកម្រិតអនុវត្តពីសំណាក់រដ្ឋាភិបាលបច្ចុប្បន្ន។ អ្នកសង្កេតការណ៍ពីខាងក្រៅទិទៀនប្រការដែលថា រដ្ឋាភិបាលរារាំងតុលាការ ECCC ពីអនុវត្តការងាររបស់ខ្លួនដោយកំហិត និងមិនបានជូនដំណឹងគ្រប់គ្រាន់ដល់សាធារណជនអំពីតុលាការនេះ។ ពួកគេក៏បានអះអាងផងដែរលើទស្សនៈទានចង្អៀតចង្អល់អំពីអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលតុលាការនេះប្រកាន់យក នៅពេលពិចារណាអំពីអំពើហឹង្សាខាងយេនឌ័រ។ តុលាការ ECCC មិនបានគិតគូរអំពីអត្តសញ្ញាណខុសៗគ្នានៃយេនឌ័រឡើយ ទោះបីប្រការនេះមានឥទ្ធិពលតិចតួចមកលើគោលនយោបាយយេនឌ័ររបស់ប្រទេសនៅក្នុងសម័យកាលក្រោយជម្លោះរហូតដល់ពេលនេះក៏ដោយៈ គោលនយោបាយយេនឌ័របន្តផ្តោតជាពិសេស តែលើស្ត្រី។ នៅក្នុងសហគមន៍គោលនយោបាយសន្តិភាពអាល្លឺម៉ង់ សញ្ញាណពិសេសអំពីយេនឌ័ររបស់តុលាការ ECCC មិនបានទទួលការយកចិត្តទុកដាក់បានច្រើនឡើយ ទោះបីនេះជាកិច្ចការខុសគ្នាមួយនៅក្នុងការស្រាវជ្រាវខាងយេនឌ័រតាមបែបសកលវិទ្យាល័យក៏ដោយ។

ការសន្និដ្ឋាន

រាល់វិធានយុត្តិធម៌អន្តរកាលមានសក្តានុពល និងដែនកំណត់ នៅពេលពាក់ព័ន្ធជាមួយការអនុវត្តយុត្តិធម៌យេនឌ័រនៅក្នុងសង្គមនាសម័យកាលក្រោយសង្គ្រាម។ ការអនុវត្តវិធាននេះ មិនអាចធ្វើឡើងដាច់ដោយឡែកឡើយ ប៉ុន្តែត្រូវតែធ្វើឡើងនៅក្នុងបង្គុំជាមួយកំណែទម្រង់ស៊ីជម្រៅសំខាន់ៗនៅក្នុងរដ្ឋ ប្រព័ន្ធច្បាប់ សេដ្ឋកិច្ច និងសង្គម។ គោលដៅគួរតែជាយុត្តិធម៌សង្គម ការពង្រឹងនូវការអនុវត្ត និងការគោរពសិទ្ធិមនុស្សរបបប្រជាធិតេយ្យ ការលុបបំបាត់អំពើពុករលួយ ក៏ដូចជា ការកែលម្អពិតប្រាកដនៅក្នុងរចនាសម្ព័ន្ធច្បាប់ និងសេដ្ឋកិច្ច សម្រាប់ក្រុមប្រជាពលរដ្ឋក្រីក្រ និងទន់ខ្សោយ។ ការលើកកំពស់វរជននៅក្នុងមូលដ្ឋាន គឺជាការជួយដល់របបយោធានិយម និងបង្កើតឲ្យមានការប្រើប្រាស់អំណាចដោយបំពានជាថ្មីឡើងវិញ។ ការបង្កើនវិសមភាពសង្គម និងការប្រមូលផ្តុំធនធាននៅក្នុងកណ្តាប់ដៃវរជនចាស់/ថ្មី នៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ គឺជាឧបសគ្គចំពោះដំណើរការសន្តិភាព និងប្រជាធិបតេយ្យនៅក្នុងរយៈពេលមធ្យម

និងរយៈពេលវែង ក៏ដូចជា ចំពោះការកែប្រែសម្រាប់រយៈពេលយូរអង្វែងនៃឋានានុក្រមយេនឌ័រ និងរវាងជំនាន់មនុស្សផងដែរ។ ប្រសិនបើរដ្ឋ និងអ្នកពាក់ព័ន្ធអន្តរជាតិមិនចាត់វិធានការណាមួយទេនោះ ឬ គ្រាន់តែពង្រឹងក្រុមដែលភាគច្រើនជា វរជនមិនស្របច្បាប់នៅតាមមូលដ្ឋាននៅក្នុងរយៈពេលខ្លី (និងដែលមានទស្សនៈចង្អៀតចង្អល់) ដោយជឿថា ក្រុមវរជនទាំងនេះអាចបង្កើតឲ្យមានសណ្ដាប់ធ្នាប់សង្គម គេនឹងមានហានិភ័យនៃបង្កើតឡើងវិញនូវការរំលោភបំពានអំណាចជាលក្ខណៈប្រព័ន្ធ អំពើផ្ដាច់ការនិយម និងយោធានិយម។

ជាគោលការណ៍ បាតុភូតទាំងនេះមានចែងនៅក្នុងទម្រង់នៃរបបយោធាដែលភាគច្រើនជាបុរសនិងនៅក្នុងអំពើហឹង្សាព្រហ្មទណ្ឌនិងអំពើហឹង្សាខាងយេនឌ័រ។លើសពីនេះការបង្កើតរបបយោធានិយមឡើងវិញ គឺជាការផ្ដល់ឱកាសដល់ក្រុមហ៊ុនខ្នាតតូចដែលផលិតអាវុធ និងឈ្មួញអាវុធ ចូលរួមនៅក្នុងជំនួញដែលផ្ដល់កម្រៃច្រើន ដោយផ្គត់ផ្គង់អាវុធដល់ជនដៃដល់ជាអ្នកប្រព្រឹត្តអំពើហឹង្សានៅក្នុងមូលដ្ឋាន ក្នុងប្រទេសនានានៅសម័យក្រោយជម្លោះ ទាំងដោយស្របច្បាប់ និងល្មើសច្បាប់។ ជនរងគ្រោះពីអំពើហឹង្សាមិនមែនមានត្រឹមតែជាស្ត្រីនិងកុមារ - កុមារី និងកុមារាប៉ុណ្ណោះទេ ប៉ុន្តែក៏ជាបុរសនៅក្នុងស្ថានភាពខុសៗគ្នា និងអាយុខុសគ្នា ក៏ដូចជា ប្រជាពលរដ្ឋដែលមានទំនោរខាងផ្លូវភេទ និងអត្តសញ្ញាណខាងយេនឌ័រខុសគ្នាផងដែរ។ ឧក្រិដ្ឋកម្មឆ្លងដែនដោយក្រុមជនពាលមិនត្រឹមតែមាននៅហ្កាតេម៉ាឡា ឬ អាហ្វ្រិកខាងត្បូងប៉ុណ្ណោះទេ ហើយឧក្រិដ្ឋកម្មតូចតាចប្រចាំថ្ងៃនៅក្នុងប្រទេសជាច្រើនក្នុងសម័យកាលក្រោយជម្លោះគឺជាភស្តុតាងអំពីភាពចាំបាច់បន្ទាន់ក្នុងការដាក់ឲ្យអនុវត្តវិធានបែបថ្មីខាងយេនឌ័រ ដែលបង្កើតឡើងដើម្បីផ្សព្វផ្សាយឲ្យដល់ទាំង បុរស និងកុមារា។ ការយកចិត្តទុកដាក់បន្ថែមទៀតគួរតែផ្ដោតលើអំពើហឹង្សាខាងផ្លូវភេទ ដែលប្រព្រឹត្តមកលើកុមារា និងបុរស នៅក្នុងអំឡុងពេលសង្គ្រាម។

អំពើហឹង្សាខាងផ្លូវភេទដែលប្រព្រឹត្តមកលើបុរស និងកុមារា ដែលសព្វថ្ងៃនេះបានទទួលការយកចិត្តទុកដាក់ត្រឹមតិចតួច នៅក្នុងគោលនយោបាយសន្តិភាព យេនឌ័រ និងសន្តិសុខ ឬ សិទ្ធិមនុស្ស និងច្បាប់អន្តរជាតិ ក៏ដូចជា ផលប៉ះពាល់របស់វាមកលើអត្តសញ្ញាណយេនឌ័ររបស់ជនរងគ្រោះ កិត្តិយសរបស់ពួកគេ និងអន្តរកម្មជាបន្តរវាងបុរស និងស្ត្រី ក៏ត្រូវតែយកមកពិចារណាឲ្យបានខ្លាំងក្លាជាងមុនផងដែរ។ ការទទួលបានយុត្តិធម៌នៅក្រោយដំណាក់កាលសង្គ្រាម ច្រើនតែនៅតែជាសុបិនដែលមិនទាន់សម្រេចបានសម្រាប់បុរសដែលបានរងការបំពារបំពានខាងផ្លូវភេទ និងដែលបានរួចជីវិតពីការរំលោភបំពានដោយអំពើហឹង្សា។

សេវាសន្តិសុខទាំងអស់ត្រូវតែរ៉ាប់រងការទទួលខុសត្រូវលើ ទង្វើរបស់ខ្លួន។ ទាក់ទងនឹងជនដៃដល់ មិនត្រឹមតែកងកម្លាំងសន្តិសុខរបស់រដ្ឋ ជាពិសេស ឈ្មួញសង្គ្រាម ឬ

យុទ្ធជននៅក្នុងអង្គភាពទ័ពព្រៃប៉ុណ្ណោះទេ ដែលត្រូវតែទទួលខុសត្រូវ ប៉ុន្តែទាំងអ្នកដែល ធ្វើការនៅក្នុងក្រុមហ៊ុនសន្តិសុខឯកជនផងដែរ ដែលតាមធម្មតាគឺបុរស និងជាញឹកញាប់ គឺជាអតីតយុទ្ធជនមកពីប្រទេសខុសៗគ្នា។ ជាញឹកញាប់ ពួកគេត្រូវបានរដ្ឋាភិបាល និងអ.ស.ប ជួលដើម្បីបម្រើការនៅ ក្នុងបេសកកម្មរក្សាសន្តិភាព និងបង្កអសន្តិសុខ និងអស្ថិរភាព តាមរយៈអំពើហឹង្សា(ខាងផ្លូវភេទ)របស់ពួកគេ ដែលមិន បានទទួលការដាក់ទណ្ឌកម្ម។ ទោះបីក្រុមហ៊ុន សន្តិសុខពឹងផ្អែកលើក្រមអនុវត្ត របស់ខ្លួនផ្ទាល់ក៏ដោយ ឬ បទប្បញ្ញត្តិអំពីនិទណ្ឌភាពរបស់អ.ស.ប ពួកគេភាគច្រើនប្រតិ បត្តិការនៅក្នុងលក្ខខណ្ឌមិនច្បាស់លាស់ទាក់ទងនឹងនិទណ្ឌភាព ជាពិសេស ទាក់ទង នឹងការរំលោភបំពានខាងផ្លូវភេទ។ ទំនាក់ទំនងរវាងក្រុមអ្នកជ្រុលនិយមខាង សាសនា និងយេនឌ័រ ក៏គួរតែយកមកវិភាគផងដែរ។ ជំហានសំខាន់មួយទៀតដែលគួរតែយកចិត្តទុកដាក់ផងដែរនោះ គឺចំណងទាក់ទងរវាង អ្នកជ្រុលនិយមខាងសាសនា និងយេនឌ័រ។ នៅទីនេះ ឆន្ទៈក្នុងការបង្កអំពើហឹង្សា មិនមែនជារឿងតែមួយនៃដើមហេតុ ប៉ុណ្ណោះទេ។ នៅក្នុងប្រទេស មួយចំនួនក្នុងសម័យកាលក្រោយជម្លោះ ដែលរួមទាំង រដ្ឋអ៊ីស្លាមផងដែរ ពួកជ្រុលនិយមនៃវិហារប៉ង់តេកូស្តាល់ មកពីស.រ.អា ផ្តោតគោលដៅជាពិសេសលើប្រជាជនដែល បាក់ស្បាតតាមរយៈការសន្យាជួយផ្តល់ការសង្គ្រោះ និងចាត់ទុកខ្លួនឯងដូចជាអ្នកជួយទំនុកបម្រុងដែលនេះជាស្ថានភាពដែលជនភៀសខ្លួន ស៊ីរី នៅប្រទេសហ្សកដង់បានជួបប្រទះ ក្នុងពេលដែលពួកគេគេចខ្លួនពីសង្គ្រាមស៊ីវិល។ ទន្ទឹមនឹងនេះ ពួកគេប្រមាថ និងផ្គន្ទា សិទ្ធិមនុស្សរបស់ស្ត្រីជនស្រឡាញ់ភេទដូចគ្នា និងបង្ហាញពីអរិយភាពចំពោះសកម្មជនសិទ្ធិទាំងនេះ។

ទស្សនវិស័យខាងនយោបាយ-យេនឌ័រអំពីយុត្តិធម៌អន្តរកាលសម្រាប់សង្គមនានានៅក្នុង អន្តរកាល ដែលតាមធម្មតាគឺជាមនុស្សភាគច្រើន និងមិនមែនជាក្រុមតូចតាចឡើយដូចដែលបាន លើកស្នើនៅក្នុងគោលការណ៍ណែនាំនានា។ កង្វល់នានាខាងសិទ្ធិមនុស្សនៅក្នុងមូលដ្ឋាន ស្ត្រី កុមារ យុវជន អ្នកមានផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ និងអង្គការLGBTI ក៏ដូចជាអ្នកសារព័ត៌មាននានា បានក្លាយជាអ្នករងគ្រោះ នៅចំពោះមុខគោលដៅយុទ្ធសាស្ត្ររយៈពេលខ្លីនៃការបង្កើតអង្គភាពរដ្ឋបាលនៅតាមមូលដ្ឋាន ឲ្យបានឆាប់រហ័សតាមតែអាចធ្វើបាន។ កង្វល់ទាំងនោះថ្កោលទោសបណ្តាញបរិបាលកិច្ចដែលគ្មានតម្លាភាពនៅក្រោមរដ្ឋបាលនៃ ក្រុមវរជនចាស់/ថ្មី នៅក្នុងការស្វែងរក និងចែកចាយធនធាន (ដូចជា ដីធ្លី មូលនិធិអភិវឌ្ឍន៍ ពីម្ចាស់ជំនួយនានា និងធនធានរ៉ែ) និងអំពាវនាវឲ្យមានសន្តិភាពរយៈពេលយូរអង្វែង និងដំណើរការអភិវឌ្ឍន៍។ កង្វល់ទាំងនោះរួមមាន ការធ្វើប្រជាធិបតេយ្យភាវូបនីយកម្ម និងការ ធ្វើសមិទ្ធិកម្មសិទ្ធិមនុស្សយុត្តិធម៌យេនឌ័រ និងការកំចាត់អំពើពុករលួយ ពោលគឺ គោលការណ៍សំខាន់ៗនៃអភិបាលកិច្ចល្អ។ ការទាមទារសំខាន់ៗរបស់ពួកគេកំពុង តែធ្លាក់កាន់ តែ ច្រើនឡើងចំត្រចៀកថ្លង់ដែលជាអ្នកកសាងផែនការរបស់រដ្ឋ និងម្ចាស់ជំនួយនានា សូម្បីតែសន្តិភាព និងផែនការសកម្មភាពអភិវឌ្ឍន៍គោលនយោបាយយេនឌ័រ និងយុទ្ធសាស្ត្រសិទ្ធិមនុស្ស ទាមទារឲ្យរួមបញ្ចូលប្រការនេះក៏ដោយ។ បញ្ហានេះធ្វើឲ្យ ការផ្តោតជាសំខាន់លើតម្រូវការទូលំទូលាយដើម្បីធ្វើឲ្យមានការគោរពសិទ្ធិមនុស្ស និងយុត្តិធម៌យេនឌ័រ កាន់តែមានសារៈសំខាន់។